# វិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមា សម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ

(វិធាននៃលសាន់ម៉ាន់ដឺឡា)

សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ
ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ (លេខ A / RES / 70 / 175)

អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

ស៊ុយអែត
Sverige

ឧបត្ថម្ភថវិកាដោយប្រទេសស៊ុយអែត

*0000000113*

ចែកជូនដោយឥតគិតថ្លៃ

ឯកសារនេះ បោះពុម្ពផ្សាយក្រោយជំនួយថវិការបស់ប្រទេសស៊ុយអែត។ មាតិកា ឬខ្លឹមសារនៅក្នុងឯកសារនេះ គឺជាទំនួលខុសត្រូវទាំងស្រុងរបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងមិនឆ្លុះaបញ្ចាំងអំពីទស្សនៈ ឬការយល់ឃើញណាមួយរបស់ប្រទេសស៊ុយអែតឡើយ។

ឧបសម្ព័ន្ធ

(នៃសេចក្តីសម្រេចរបស់មហាសន្និបាតរបស់អង្គការសហប្រជាជាតិលេខ ៧០/១៧៥ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៥)

# វិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ (វិធានណែលសាន់ម៉ាន់ដឺឡា)

**កថាដើម ១**

វិធានខាងក្រោមនេះនឹងមិនរៀបរាប់លម្អិតអំពីប្រព័ន្ធគំរូនៃស្ថាប័នទទួលបន្ទុកអនុវត្តទោសឡើយ។ ដោយផ្អែកលើមតិទូទៅ នៃគំនិតស្របគ្នាអំពីធាតុសំខាន់ៗនៃប្រព័ន្ធដែលសមស្របបំផុតសម្រាប់បច្ចុប្បន្ននេះ វិធាននេះ មានគោលដៅត្រឹមតែរៀបរាប់អំពីអ្វីដែលត្រូវបានទទួលយកជាទូទៅថាជាគោលការណ៍ និងការអនុវត្តល្អ ក្នុងការប្រព្រឹត្តទៅលើជនជាប់ឃុំ និងការគ្រប់គ្រងពន្ធនាគារប៉ុណ្ណោះ។

**កថាដើម ២**

១. ក្នុងពិភពលោកទាំងមូលនេះ ដោយសារមានលក្ខណៈខុសប្លែកពីគ្នាច្រើនលើសលុបពេក ទាំងក្នុងវិស័យច្បាប់ សេដ្ឋកិច្ច សង្គមកិច្ច និងផ្នែកភូមិសាស្ត្រផងនោះ គេជឿជាក់ថា គេមិនអាចយកវិធានទាំងអស់នេះទៅប្រើនៅគ្រប់ទីកន្លែងបានគ្រប់ពេលវេលាទេ។ វិធានទាំងនេះ គ្រាន់តែជាឧបករណ៍សម្រាប់ជំរុញឲ្យមានការខំប្រឹងខ្នះខ្នែងជាអចិន្ត្រៃយ៍ក្នុងការពុះពារយកជ័យជំនះ ទៅលើការលំបាកសព្វបែបយ៉ាង ដែលគេតែងតែជួបប្រទះក្នុងពេលអនុវត្ត និងការផ្សព្វផ្សាយទ្រឹស្តី ព្រោះវិធានទាំងនេះជាលក្ខខណ្ឌអប្បបរមាដែលអង្គការសហប្រជាជាតិទទួលស្គាល់ស្គាល់ថាមានលក្ខណៈសមស្រប។

២. ម៉្យាងវិញទៀត វិធានទាំងនេះគ្របដណ្តប់ទៅលើវិស័យមួយដែលកំពុងទទួលបាននូវគំនិតថ្មីៗជាបន្តបន្ទាប់។ វិធានទាំងនេះមិនមានគោលបំណងរារាំងដល់ការដកស្រង់បទពិសោធ និងការអនុវត្តដែលកំពុងនៅជាធរមានឡើយ ល្គឹកណាតែបទពិសោធនិងការអនុវត្តទាំងនោះមានលក្ខណៈចុះសម្រុងជាមួយគោលការណ៍ និងគោលបំណងទាំងឡាយដែលមានក្នុងវិធាននេះទាំងមូល។ ក្នុងស្មារតីនេះ រដ្ឋបាលគ្រប់គ្រងពន្ធនាគារថ្នាក់កណ្តាលនៅតែមានលទ្ធភាពផ្តល់មូលហេតុសមស្របក្នុងការបង្កើតវិធានផ្សេងៗក្រៅពីវិធានទាំងនេះ។

**កថាដើម ៣**

១. ផ្នែក I នៃវិធាននេះ មានវិសាលភាពគ្របដណ្តប់លើការគ្រប់គ្រងពន្ធនាគារទូទៅ ហើយអាចប្រើបានចំពោះជនជាប់ឃុំគ្រប់ប្រភេទ ទាំងក្នុងបទល្មើសព្រហ្មទណ្ឌនិងរដ្ឋប្បវេណី ជនជាប់ឃុំដែលពុំទាន់ត្រូវបាន

ជំនុំជម្រះ ឬជនជាប់ឃុំដែលទទួលការផ្តន្ទាទោសស្ពាល ហើយនិងអ្នកមានទោសស្រាលៗដែលស្ថិតនៅក្នុង វិធានការសន្តិសុខ ឬ វិធានការអប់រំកែប្រែសម្រេចដោយចៅក្រម។
២. ផ្នែក II គឺជាវិធានសម្រាប់អនុវត្តទៅលើប្រភេទនៃករណីពិសេស ដែលគេចែកចេញជាជំពូកផ្សេងៗគ្នា។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ វិធានក្នុងផ្នែក (ក) ដែលសម្រាប់ប្រើចំពោះជនជាប់ឃុំដែលតុលាការកាត់ទោសហើយ ក៏អាចយកទៅប្រើលើជនជាប់ឃុំដែលមានចែងក្នុងផ្នែក (ខ), (គ) និង (ឃ) បានដែរ កុំឲ្យតែមានទំនាស់ជាមួយនឹងច្បាប់សម្រាប់គ្រប់គ្រងជនជាប់ឃុំទាំងនេះ និងត្រូវប្រើប្រាស់ជាប្រយោជន៍ដល់ពួកគេ។

**កថាដើម ៤**

១. ច្បាប់វិន័យទាំងនេះមិនមែនប្រាថ្នាដាក់កម្រិត ឲ្យយកទៅប្រើនៅពន្ធនាគារសម្រាប់មនុស្សក្មេងៗឡើយ ដូចជាពន្ធនាគារសម្រាប់អនីតិជន ឬសាលាអប់រំកែប្រែ។ ប៉ុន្តែ ជាទូទៅ ផ្នែក I អាចយកទៅប្រើបាននៅក្នុងពន្ធនាគារដែលមានចរិតលក្ខណៈដូចនេះ ។

២. ជំពូកជនជាប់ឃុំក្មេងៗ គឺដៅទៅលើពួកជនជាប់ឃុំក្មេងៗទាំងអស់ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ តុលាការសម្រាប់អនីតិជន។ តាមទម្លាប់, ពួកក្មេងៗទាំងនេះ ពុំត្រូវកាត់ទោសដាក់ក្នុងពន្ធនាគារឡើយ ។

**I. ច្បាប់វិន័យសម្រាប់ការអនុវត្តជាទូទៅ**

**គោលការណ៍ជាមូលដ្ឋាន**

*វិធានទី១*

សេចក្តីថ្លៃថ្នូរ និងតម្លៃមនុស្សជាតិរបស់ជនជាប់ឃុំទាំងអស់គួរត្រូវបានគោរព។ គ្មានជនជាប់ឃុំណាម្នាក់ត្រូវបានបង្ខំឱ្យទទួលរងទារុណកម្ម ហើយជនជាប់ឃុំទាំងអស់ត្រូវបានការពារពីការធ្វើទារុណកម្ម និងអំពើឃោរឃៅ អំពើអមនុស្សធម៌ ឬអំពើបន្ថោកបន្ទាប ឬទណ្ឌកម្ម ផ្សេងទៀត ដែលគ្មានករណីណាមួយត្រូវសំអាងជាហេតុផលឡើយ។ សុវត្ថិភាព និងសន្តិសុខរបស់ជនជាប់ឃុំ បុគ្គលិក អ្នកផ្តល់សេវា និងអ្នកសួរសុខទុក្ខត្រូវបានធានាគ្រប់ពេល។

*វិធាន ២*

១. បទបញ្ញត្តិដូចតទៅនេះ ត្រូវយកទៅអនុវត្តដោយមិនឲ្យមានលំអៀងឡើយ។ មិនត្រូវឲ្យមានការប្រកាន់ពូជសាសន៍ ពណ៌សំបុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិដទៃៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ ស្ថានភាពកំណើត ឬស្ថានភាពដទៃៗទៀតឡើយ។

២ ដើម្បីដាក់ឲ្យអនុវត្តគោលការណ៍មិនរើសអើង រដ្ឋបាលពន្ធនាគារ ត្រូវគិតគូរពីសេចក្តីត្រូវការរបស់ជនជាប់ឃុំម្នាក់ៗ ជាពិសេស ក្រុមដែលងាយរងគ្រោះបំផុតនៅក្នុងពន្ធនាគារ។ ត្រូវចាត់វិធានការការពារ និងលើកកំពស់សិទ្ធិជនជាប់ឃុំដែលមានសេចក្តីត្រូវការពិសេស ហើយមិនត្រូវបានចាត់ទុកថាជាការរើសអើងឡើយ។

*វិធាន ៣*

ការដាក់ពន្ធនាគារ ហើយនិងវិធានការដទៃទៀត ដែលបណ្តាលឲ្យជនជាប់ឃុំត្រូវកាត់ផ្តាច់ពីការទាក់ទងជាមួយអ្នកដទៃគឺអាចធ្វើបានក្នុងគោលដៅមិនឱ្យមានការអនុវត្តសិទ្ធិស្វ័យសម្រេចតាមរយៈការដូកហូតនូវសេរីភាព។ ដូច្នេះក្រៅអំពីការឃុំឃាំងដោយមានមូលហេតុត្រឹមត្រូវច្បាស់លាស់ ហើយនិងការរក្សាវិន័យក្នុងពន្ធនាគារ របបគ្រប់គ្រងនៅក្នុងពន្ធនាគារមិនត្រូវបង្កើនសេចក្តីទុក្ខសោកឈឺចាប់ទៅលើពួកជនជាប់ឃុំដែលកំពុងតែមានការឈឺចាប់នោះទៀតឡើយ ។

*វិធាន ៤*

១. គោលដៅ និងមូលហេតុនៃការកាត់ទោសដាក់ពន្ធនាគារ ឬតាមមធ្យោបាយឯទៀត ដើម្បីមិនឲ្យសាមីខ្លួនមានសេរីភាព គឺវិសេសបំផុតដើម្បីការពារសង្គមមនុស្សកុំឲ្យមានអំពើឧក្រិដ្ឋ។ គោលដៅនេះនឹងសម្រេចទៅបាន លុះត្រាតែមានការអប់រំឲ្យបានខ្ពង់ខ្ពស់បំផុតដល់ជនជាប់ឃុំ ដែលកំពុងនៅក្នុងពន្ធនាគារ ហើយពេលចេញពីពន្ធនាគារវិញ បុគ្គលនេះមិនត្រឹមតែក្លាយជាមនុស្ស ដែលមានបំណងចង់គោរពច្បាប់តែប៉ុណ្ណោះទេ តែក្លាយទៅជាមនុស្សមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រតិបត្តិតាមច្បាប់ និងប្រកបរបរចិញ្ចឹមជីវិតដោយខ្លួនឯងទៀតផង។

២. ក្នុងទិសដៅនេះ រដ្ឋបាលពន្ធនាគារត្រូវប្រើគ្រប់មធ្យោបាយដែលសមរម្យ និងដែលអាចរកបានទាំងមធ្យោបាយអប់រំ មធ្យោបាយដោះស្រាយបញ្ហា មធ្យោបាយផ្នែកសីលធម៌ និងខាងគំនិតស្មារតី ហើយនិង

មធ្យោបាយដទៃទៀត ព្រមទាំងជំនួយគ្រប់បែបយ៉ាងដែលអាចរកបាន ហើយត្រូវព្យាយាមប្រើវាតាមលំនាំនៃសេចក្តីត្រូវការក្នុងការគ្រប់គ្រងជនជាប់ឃុំមួយរូបៗ។

*វិធាន ៥*

១. របបគ្រប់គ្រងនៅក្នុងពន្ធនាគារ ត្រូវធ្វើយ៉ាងណាកុំឲ្យការរស់នៅក្នុងពន្ធនាគារខុសគ្នាឆ្ងាយពេកអំពីជីវិត ដែលប្រកបដោយសេរីភាពនៅក្រៅពន្ធនាគារ គឺដើម្បីជួយសម្រាលបន្ទុកដល់ជនជាប់ឃុំ ហើយនិងបង្កើនការគោរពដល់សេចក្តីថ្លៃថ្នូររបស់គេក្នុងនាមជាមនុស្ស ។

២. រដ្ឋបាលពន្ធនាគារ ត្រូវផ្តល់កន្លែងសមស្របឲ្យជនជាប់ឃុំស្នាក់នៅ និងរៀបចំកែសម្រួលតាមការជាក់ស្តែង ដើម្បីធានាថាជនជាប់ឃុំដែលមានពិការភាពផ្លូវកាយ ផ្លូវចិត្ត ឬពិការភាពផ្សេងទៀត អាចរស់នៅក្នុងពន្ធនាគារយ៉ាងពេញលេញ និងមានប្រសិទ្ធភាព ផ្អែកលើគោលការណ៍សមធម៌។

## ការគ្រប់គ្រងសំណុំរឿងជនជាប់ឃុំ

*វិធានទី៦*

គ្រប់ពន្ធនាគារ ត្រូវមានប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ជនជាប់ឃុំត្រឹមត្រូវ។ ប្រព័ន្ធសំណុំរឿងនេះអាចជារបាយការណ៍ទិន្នន័យមូលដ្ឋានអេឡិចត្រូនិច ឬសៀវភៅកត់ឈ្មោះដែលទំព័រមានបង់លេខ និងចុះហត្ថលេខា។ ត្រូវមាននីតិវិធីដើម្បីធានាសុវត្ថិភាពសៀវភៅសវនកម្ម និងទប់ស្កាត់ការចូល ឬការផ្លាស់ប្តូរព័ត៌មានក្នុងប្រព័ន្ធដោយគ្មានការអនុញ្ញាត។

*វិធានទី៧*

គ្មានមនុស្សណាម្នាក់ត្រូវបានទទួលដាក់ពន្ធនាគារ ដោយមិនមានដីកាឃុំខ្លួនឡើយ។ បន្ទាប់ពីការទទួលជនជាប់ឃុំម្នាក់ៗ ត្រូវបញ្ចូលព័ត៌មានខាងក្រោមក្នុងប្រព័ន្ធគ្រប់គ្រងសំណុំរឿងជនជាប់ឃុំ៖

(ក) ព័ត៌មានជាក់លាក់ បង្កភាពងាយស្រួលក្នុងការកំណត់អត្តសញ្ញាណ ការគោរពយេនឌ័រ

(ខ) មូលហេតុសម្រាប់ដីកាឃុំខ្លួន និងអាជ្ញាធរទទួលខុសត្រូវ និងកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងឃាត់ខ្លួន។

(គ) ថ្ងៃ និងម៉ោងចូលពន្ធនាគារ ដោះលែង និងផ្ទេរ

(ឃ) របួសជាក់ស្តែងណាមួយ និងបណ្តឹងពីការធ្វើបាបមុនពេលចូលពន្ធនាគារ

(ង) បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់ជនជាប់ឃុំ

(ច) ឈ្មោះសមាជិកគ្រួសារ និងកូន និងអាយុកូនៗ ប្រសិនមាន ទីកន្លែង និងពន្ធនាគារ ឬស្ថានភាពអាណាព្យាបាល

(ឆ) អាសយដ្ឋានទំនាក់ទំនងបន្ទាន់ និងព័ត៌មានរបស់សាច់ញាតិជិតស្និទ្ធរបស់ជនជាប់ឃុំ។

*វិធានទី៨*

ប្រសិនអាចធ្វើទៅបាន នៅក្នុងអំឡុងពេលជាប់ពន្ធនាគារ ត្រូវដាក់បញ្ចូលព័ត៌មានខាងក្រោមទៅក្នុងប្រព័ន្ធគ្រប់គ្រងសំណុំរឿងជនជាប់ឃុំ៖

(ក) ព័ត៌មានទាក់ទងនឹងនីតិវិធីតុលាការ រួមទាំងកាលបរិច្ឆេទសវនាការតុលាការ និងបណ្តឹងតវ៉ាផ្នែកផ្លូវច្បាប់

(ខ) របាយការណ៍វាយតម្លៃបឋម និងរបាយការណ៍ចំណាត់ថ្នាក់

(គ) របាយការណ៍ទាក់ទងនឹងការប្រព្រឹត្ត និងវិន័យ

(ឃ) សំណើ និងការតវ៉ា រួមទាំងការចោទប្រកាន់អំពីការធ្វើទារុណកម្ម ឬអំពើឃោរឃៅ អំពើអមនុស្សធម៌ ឬអំពើបន្ថោកបន្ទាប ឬទណ្ឌកម្ម លើកលែងតែវាជាព័ត៌មានដែលត្រូវរក្សាការសម្ងាត់។

(ង) ព័តមានស្តីពីការដាក់ទណ្ឌកម្មវិន័យ

(ច) ព័ត៌មានស្តីពីស្ថានភាព និងមូលហេតុនៃរបួសស្នាម ឬមរណភាព និងក្នុងករណីក្រោយមកទៀត ទីកន្លែងដែលត្រូវបញ្ជូនសាកសព។

*វិធានទី៩*

រាល់របាយការណ៍ទាំងអស់ដែលបានរៀបរាប់នៅក្នុងវិធានទី៧ និងទី៨ ត្រូវរក្សាការសម្ងាត់ និងត្រូវផ្តល់ឱ្យតែចំពោះអ្នកទទួលខុសត្រូវ ដែលត្រូវការរបាយការណ៍ទាំងនេះប៉ុណ្ណោះ។ ជនជាប់ឃុំម្នាក់ៗ ត្រូវបានផ្តល់សិទ្ធិចូលមើលរបាយការណ៍ទាំងនេះ ដែលទាក់ទងចំពោះពួកគេ អាស្រ័យទៅលើវិធានមើលឯកសារដែលអនុញ្ញាតដោយច្បាប់ក្នុងស្រុក និងមានសិទ្ធិទទួលបានច្បាប់ថតចម្លងនៃរបាយការណ៍នេះ ពេលចេញពីពន្ធនាគារ។

*វិធានទី១០*

ប្រព័ន្ធគ្រប់គ្រងសំណុំរឿងជនជាប់ឃុំ ក៏ត្រូវបានប្រើផងដែរដើម្បីបង្កើតទិន្នន័យដែលជឿទុកចិត្តបានអំពីនិន្នាការនានាទាក់ទងនឹងនឹងចរិតលក្ខណៈនៃមនុស្សក្នុងពន្ធនាគារ រួមមានអត្រានៃការប្រើប្រាស់បន្ទប់ពន្ធនាគារ ដើម្បីបង្កើតជាមូលដ្ឋានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តផ្អែកលើភ័ស្តុតាង។

**ការបែងចែកជនជាប់ឃុំតាមប្រភេទ**

*វិធាន ១១*

ប្រភេទជនជាប់ឃុំខុសៗគ្នា ត្រូវឃុំក្នុងពន្ធនាគារ ឬផ្នែកនៃពន្ធនាគារដាច់ដោយឡែកៗពីគ្នាដោយយោងទៅតាម ភេទ អាយុ ប្រវត្តិប្រព្រឹត្តបទឧក្រិដ្ឋ ហេតុផលខាងផ្លូវច្បាប់សម្រាប់ការឃុំខ្លួនរបស់គេ ព្រមទាំងសេចក្តីចាំបាច់នានានៃការប្រព្រឹត្តចំពោះពួកគេ មានដូចជា៖

(ក) ជនជាប់ឃុំប្រុស និងជនជាប់ឃុំស្ត្រី ត្រូវដាក់ឃុំដាច់ដោយឡែក និងឲ្យបានឆ្ងាយពីគ្នាតាមលទ្ធភាពដែលអាចធ្វើទៅបាន។ ចំពោះពន្ធនាគារដែលទទួលយកទាំងជនជាប់ឃុំប្រុស និងជនជាប់ឃុំស្រី នោះបរិវេណសម្រាប់ដាក់ជនជាប់ឃុំស្រីត្រូវតែនៅដាច់ដោយឡែកពីបរិវេណសម្រាប់ជនជាប់ឃុំប្រុសជាដាច់ខាត។

(ខ) ជនជាប់ឃុំដែលមិនទាន់ត្រូវបានជំនុំជម្រះទោសត្រូវតែដាក់ឲ្យនៅដាច់ដោយឡែកពីទណ្ឌិត

(គ) អ្នកជាប់ពន្ធនាគារដោយសារជំពាក់បំណុលគេ និងជាប់ដោយសាររឿងរដ្ឋប្បវេណី ត្រូវដាក់ឲ្យដាច់ឡែកពីជនជាប់ឃុំដែលត្រូវបានរកឃើញថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

(ឃ) ជនជាប់ឃុំអនីតិជន ត្រូវដាក់ឲ្យដាច់ឡែកពីជនជាប់ឃុំដែលជាមនុស្សពេញវ័យ។

**ទីកន្លែងសម្រាប់ជនជាប់ឃុំស្នាក់នៅ**

*វិធាន ១២*

១. ក្នុងករណីជនជាប់ឃុំអាចមានបន្ទប់ដេកម្នាក់មួយរៀងៗខ្លួន ជនជាប់ឃុំម្នាក់ៗមានសិទ្ធិដេកក្នុងបន្ទប់មួយតែម្នាក់ឯងគត់។ ប៉ុន្តែ ដោយមូលហេតុពិសេសខ្លះ ដូចជាក្នុងករណីបណ្តោះអាសន្នដែលមានភាពចង្អៀតណែនក្នុងពន្ធនាគារ រដ្ឋបាលគ្រប់គ្រងពន្ធនាគារថ្នាក់កណ្តាលអាចចាំបាច់ធ្វើបដិប្បញ្ញត្តិទៅនឹងវិធាននេះបាន។ ប៉ុន្តែបើជៀសវាងបាន គួរកុំដាក់ជនជាប់ឃុំពីរនាក់ឲ្យនៅដេកក្នុងបន្ទប់ឃុំឃាំងជាមួយគ្នា។

២. ប្រសិនបើជនជាប់ឃុំដេកក្នុងបន្ទប់រួមគ្នា គេត្រូវជ្រើសយកតែជនជាប់ឃុំប្រភេទណាដែលអាចរស់នៅជាមួយគ្នាបានឲ្យនៅក្នុងបន្ទប់ជាមួយគ្នា ហើយត្រូវឲ្យមានការត្រួតពិនិត្យមើលឲ្យបានទៀងទាត់នៅវេលាយប់អាស្រ័យទៅតាមប្រភេទនៃពន្ធនាគារ។

*វិធាន ១៣*

គ្រប់កន្លែងស្នាក់នៅដែលប្រើសម្រាប់ដាក់ជនជាប់ឃុំ និងជាពិសេសកន្លែងដេកទាំងអស់ត្រូវ ស្របទៅតាមតម្រូវការផ្នែកសុខភាព ពោលគឺយកចិត្តទុកដាក់ទៅលើលក្ខណៈធាតុអាកាស និងជាពិសេសគឺត្រូវមានខ្យល់ដកដង្ហើមគ្រប់គ្រាន់ មានទំហំផ្ទៃរាបសមល្មម មានពន្លឺ កំដៅ និងខ្យល់អាកាសចេញចូលគ្រប់គ្រាន់។

*វិធាន ១៤*

នៅគ្រប់ទីកន្លែងណាដែលគេតម្រូវឲ្យជនជាប់ឃុំនៅផង ហើយធ្វើការផង គេត្រូវធានាឱ្យមានលក្ខខណ្ឌដូចខាងក្រោមនេះ ៖

(ក) ត្រូវមានបង្អួចទូលំទូលាយ ដើម្បីឲ្យជនជាប់ឃុំអាចធ្វើការ ឬអានសៀវភៅបានដោយពន្លឺថ្ងៃ ហើយឲ្យមានច្រកចំហធំៗ ដើម្បីឲ្យខ្យល់បក់បានគ្រប់គ្រាន់ ទោះជាមានឬគ្មានកង្ហារបក់ខ្យល់ក៏ដោយ ។

(ខ) ភ្លើងអំពូល ឬភ្លើងអគ្គីសនី ត្រូវឲ្យមានគ្រប់គ្រាន់និងត្រឹមត្រូវ ដើម្បីការពារកុំឲ្យខូចភ្នែកជនជាប់ឃុំនៅ ពេលអានសៀវភៅ ឬនៅពេលធ្វើការ។

*វិធាន ១៥*

បង្គន់ត្រូវឲ្យមានគ្រប់គ្រាន់សម្រាប់សេចក្តីត្រូវការរបស់ជនជាប់ឃុំគ្រប់ពេលវេលា ហើយត្រូវឲ្យមានភាពស្អាត និងសមរម្យផងដែរ។

*វិធាន ១៦*

ត្រូវមានបន្ទប់ទឹកគ្រប់គ្រាន់។ ប្រដាប់ប្រើប្រាស់ក្នុងបន្ទប់ទឹកក៏ត្រូវឲ្យមានគ្រប់គ្រាន់។ ត្រូវឲ្យមានទឹកដែលមានសីតុណ្ហភាពស្របទៅតាមធាតុអាកាសខាងក្រៅ និងត្រូវមានទឹកគ្រប់គ្រាន់សម្រាប់សេចក្តីត្រូវការចាំបាច់របស់ជនជាប់ឃុំ ដោយយោងទៅតាមលក្ខខណ្ឌអនាម័យទូទៅប្រចាំរដូវកាល និងទៅតាមលក្ខណ្ឌតំបន់ភូមិសាស្ត្រ។

*វិធាន ១៧*

គ្រប់ផ្នែកនៃពន្ធនាគារ ដែលសម្រាប់ឲ្យជនជាប់ឃុំប្រើប្រាស់ជានិច្ចជាកាល ត្រូវថែទាំ សំអាតឲ្យបានត្រឹមត្រូវនិង យ៉ាងហ្មត់ចត់គ្រប់ពេលវេលា។

**អនាម័យប្រចាំកាយ**

*វិធាន ១៨*

១. ជនជាប់ឃុំត្រូវរក្សារាងកាយបានស្អាតបាត។ ហេតុនេះ ពួកគេត្រូវតែបានផ្តល់ឲ្យនូវទឹកស្អាត ព្រមទាំងគ្រឿងបរិក្ខារ ប្រើប្រាស់ក្នុងបន្ទប់ទឹកផ្សេងៗ ដែលជាការចាំបាច់សម្រាប់សុខភាព និងភាពស្អាត ។

២. វិន័យចែងថា ជនជាប់ឃុំអាចថែរក្សាខ្លួនឲ្យមានសភាពសមរម្យជាមនុស្សដូចគេឯទៀត។ ក្នុងន័យនេះ ពន្ធនាគារត្រូវតែមានកន្លែងកាត់សក់និងកោរពុកមាត់សម្រាប់ជនជាប់ឃុំ។ ជនជាប់ឃុំប្រុសត្រូវមានលទ្ធភាពកោរពុកមាត់ឲ្យបានទៀងទាត់។

## ការស្លៀកពាក់ និងការដេក

*វិធាន ១៩*

១. រាល់ជនជាប់ឃុំណា ដែលមិនអនុញ្ញាតិឲ្យស្លៀកពាក់សម្លៀកបំពាក់ផ្ទាល់ខ្លួនរបស់គេទេ នោះពួកគេត្រូវតែបានគេផ្តល់ឲ្យនូវសម្លៀកបំពាក់ណាមួយ ដែលសមស្របទៅនឹងធាតុអាកាស និងគ្រប់គ្រាន់ដើម្បីរក្សាគេឲ្យមានសុខភាពល្អ។ សម្លៀកបំពាក់នេះទៀត ក៏មិនត្រូវធ្វើឲ្យមានលក្ខណៈបន្ថោកបន្ទាប ឬអាប់ឱនដល់ជនជាប់ឃុំឡើយ។

២. សម្លៀកបំពាក់ទាំងអស់ ត្រូវតែឲ្យស្អាត ហើយឲ្យមានលក្ខណៈសមរម្យជានិច្ច។ សម្លៀកបំពាក់ក្នុងត្រូវផ្លាស់ប្តូរនិងបោកសំអាតឲ្យបានញឹកញាប់តាមការចាំបាច់ ដើម្បីរក្សាអនាម័យប្រចាំកាយ ។

៣. តាមកាលៈទេសៈពិសេសខ្លះ នៅពេលណាគេយកជនជាប់ឃុំចេញទៅក្រៅពន្ធនាគារក្នុងគោលបំណងណាមួយដែលមានការអនុញ្ញាតិតាមច្បាប់ ជនជាប់ឃុំត្រូវតែបានអនុញ្ញាតិឱ្យស្លៀកពាក់សម្លៀកបំពាក់ផ្ទាល់ខ្លួនរបស់គេ ឬក៏សម្លៀកបំពាក់ផ្សេងៗ ដែលពុំមានលក្ខណៈលេចធ្លោខុសគេខុសឯងពេក។

*វិធាន ២០*

ប្រសិនបើគេអនុញ្ញាតឲ្យជនជាប់ឃុំស្លៀកពាក់ខោអាវផ្ទាល់ខ្លួននៅក្នុងពន្ធនាគារ អាជ្ញាធរត្រូវធានាថាខោអាវទាំងនេះត្រូវរក្សាឲ្យស្អាតបាត ហើយមានគុណភាពល្អសមល្មមប្រើបានជានិច្ច។ ចំណាត់ការបែបនេះត្រូវផ្តើមធ្វើចាប់តាំងពីថ្ងៃដែលជនជាប់ឃុំចូលមកដល់ពន្ធនាគារ។

*វិធាន ២១*

យោងទៅតាមកម្រិតរស់នៅប្រចាំតំបន់ ឬប្រចាំប្រទេសទាំងមូល ជនជាប់ឃុំគ្រប់ៗរូបត្រូវតែមានគ្រែដេកម្នាក់មួយ និងសម្ភារៈដេកដោយឡែកពីជនជាប់ឃុំឯទៀត ហើយត្រូវឲ្យស្អាត និងត្រូវផ្លាស់ប្តូរ ឲ្យបានញឹកញាប់ដើម្បីរក្សាភាពស្អាតបាត។

## ម្ហូបអាហារ

*វិធាន ២២*

១. ជនជាប់ឃុំគ្រប់រូប ត្រូវតែបានទទួលម្ហូបអាហារ ដែលផ្តល់ឲ្យដោយរដ្ឋតាមពេលម៉ោងធម្មតា។ ម្ហូបអាហារនោះ ត្រូវមានគុណភាព និងជីវជាតិអាហារគ្រប់គ្រាន់ដើម្បីសុខភាព និងកម្លាំងពលំ រស់ជាតិទទួលយកបាន និងត្រូវបានចម្អិនបានល្អ។

២. ទឹកសម្រាប់ផឹកត្រូវឲ្យមានគ្រប់គ្រាន់សម្រាប់នៅពេលណាជនជាប់ឃុំម្នាក់ៗត្រូវការ។

**ការហាត់ប្រាណនិងលេងកីឡា**

*វិធាន ២៣*

១. ជនជាប់ឃុំគ្រប់រូប ដែលមិនបានចេញទៅធ្វើការនៅខាងក្រៅពន្ធនាគារទេនោះ ត្រូវមានឱកាសហាត់ប្រាណនៅក្នុងទីធ្លាស្រឡះយ៉ាងតិចមួយម៉ោងជារៀងរាល់ថ្ងៃ ប្រសិនបើធាតុអាកាសអនុញ្ញាត។

២. ជនជាប់ឃុំអនីតិជន និងជនជាប់ឃុំនីតិជនដែលមានអាយុ និងរាងកាយសមស្រប ត្រូវឲ្យមានការហ្វឹកហាត់ខាងកាយវប្បកម្ម និងការកំសាន្តផងនៅក្នុងពេលហាត់ប្រាណ។ ក្នុងន័យនេះដែរពន្ធនាគារគួរផ្តល់ទីកន្លែង និងសំភារៈកីឡាផ្សេងៗ។

**សេវាថែទាំសុខភាព**

*វិធានទី២៤*

ការផ្តល់សេវាថែទាំសុខភាពដល់ជនជាប់ឃុំ គឺជាការទទួលខុសត្រូវរបស់រដ្ឋ។ ជនជាប់ឃុំត្រូវទទួលបានការថែទាំសុខភាពតាមស្តង់ដារដូចគ្នានឹងសេវាសុខភាពខាងក្រៅពន្ធនាគារដូច្នោះដែរ និងត្រូវមានលទ្ធភាពទទួលបានសេវាថែទាំសុខភាពដោយឥតគិតថ្លៃ និងមិនរើសអើងដោយសារស្ថានភាពផ្លូវច្បាប់របស់ពួកគេ។

សេវាថែទាំសុខភាព ត្រូវបានចាត់ចែងដោយសហការជិតស្និតជាមួយប្រព័ន្ធសុខាភិបាលសាធារណៈទូទៅ និង ធានាឱ្យមាននិរន្តរភាពនៃការព្យាបាល និងថែទាំ រួមទាំងមេរោគអេដស៍ របេង និងជំងឺឆ្លងផ្សេងៗទៀត ក៏ដូចជាចំពោះរោគញៀនផងដែរ។

*វិធានទី២៥*

១. ពន្ធនាគារនីមួយៗត្រូវមានសេវាថែទាំសុខភាព ដែលមានភារកិច្ចវាយតម្លៃ ផ្សព្វផ្សាយ ការពារ និងលើកកម្ពស់សុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្តរបស់ជនជាប់ឃុំ ដោយយកចិត្តទុកដាក់ពិសេសចំពោះជនជាប់ឃុំ ដែលត្រូវការការថែទាំសុខភាពពិសេស ឬដែលមានបញ្ហាសុខភាពដែលរារាំងដល់ការស្តារនីតិសម្បទា។

២. សេវាសុខភាពត្រូវមានសមាសភាពជាក្រុមចម្រុះ និងមានគុណវឌ្ឍិគ្រប់គ្រាន់ ក្នុងការព្យាបាលដោយឯករាជ្យ និងត្រូវមានជំនាញផ្នែកចិត្តវិទ្យា និងវិកលវិទ្យា។ ពន្ធនាគារក៏ត្រូវមានទន្តពេទ្យដែលមានគុណវុឌ្ឍិសមស្របសម្រាប់ជនជាប់ឃុំម្នាក់ៗ។

*វិធានទី២៦*

១. ផ្នែកសេវាថែទាំសុខភាព ត្រូវរៀបចំ និងថែទាឯកសារពេទ្យទៀងទាត់ ថ្មីៗ និងមានការសម្ងាត់របស់ជនជាប់ឃុំម្នាក់ៗ ហើយជនជាប់ឃុំទាំងអស់អាចអនុញ្ញាតចូលមើលឯកសាររបស់ពួកគេទៅតាមសំណើ។ ជនជាប់ឃុំអាចពឹងពាក់ឱ្យអ្នកទីបីចូលមើលឯកសាររបស់ខ្លួនបាន។

២. ឯកសារពេទ្យត្រូវបានផ្ទេរទៅផ្នែកសេវាថែទាំសុខភាពនៃស្ថាប័នទទួលនៅពេលមានការផ្ទេរជនជាប់ឃុំណាម្នាក់ ដោយត្រូវរក្សាការសម្ងាត់វេជ្ជសាស្ត្រ។

វិធានទី២៧

១. ពន្ធនាគារទាំងអស់ត្រូវធានាការទទួលការទទួលភ្លាមៗនូវការថែទាំវេជ្ជសាស្ត្រក្នុងករណីបន្ទាន់។ ជនជាប់ឃុំដែលត្រូវការការព្យាបាលពិសេសឬការវះកាត់ ត្រូវបញ្ជូនទៅស្ថាប័នជំនាញ ឬទៅមន្ទីរពេទ្យទូទៅនៅខាងក្រៅ។ ទីណាពន្ធនាគារមានមន្ទីរពេទ្យខ្លួនឯង ត្រូវមានបុគ្គលិក និង បំពាក់បរិក្ខារគ្រប់គ្រាន់ ដើម្បីព្យាបាល និងថែទាំជនជាប់ឃុំដែលត្រូវទទួលសេវាសុខាភិបាល។

២. មានតែអ្នកជំនាញការផ្នែកថែទាំងសុខភាពប៉ុណ្ណោះដែលអាចធ្វើការសម្រេចចិត្តទាក់ទងនឹងការព្យាបាល ដោយមិនត្រូវបានបំពានដោយ ឬមិនអើពើពីមន្ត្រីពន្ធនាគារដែលមិនមែនជាមន្ត្រីពេទ្យឡើយ។

*វិធាន ២៨*

នៅក្នុងពន្ធនាគាររបស់ជនជាប់ឃុំស្រី ត្រូវឲ្យមានការឧបត្ថម្ភពិសេសសម្រាប់ការថែរក្សា និងព្យាបាល ខ្លួននៅពេលមុន និងក្រោយការសម្រាលកូន។ បើអាចធ្វើបាន ត្រូវតែអនុញ្ញាតឲ្យជនជាប់ឃុំបានចេញទៅសម្រាលកូននៅក្រៅពន្ធនាគារ។ ប៉ុន្តែបើសិនណាកូនកើតនៅក្នុងពន្ធនាគារវិញ មិនត្រូវចុះនិទ្ទេសក្នុងសំបុត្រកំណើតថាទារកនោះកើតនៅក្នុងពន្ធនាគារឡើយ។

*វិធានទី២៩*

១. ការសម្រេចចិត្តអនុញ្ញាតឱ្យក្មេងស្នាក់នៅជាមួយឪពុកម្ដាយក្នុងពន្ធនាគារ គឺត្រូវផ្អែកលើផលឧត្ដមប្រយោជន៍របស់កុមារ។ ពេលអនុញ្ញាតឱ្យកុមារស្នាក់នៅក្នុងពន្ធនាគារជាមួយឪពុកម្ដាយ ត្រូវផ្ដល់សេវាដូចខាងក្រោមដល់កុមារ៖

(ក) ពេលកុមារមិនស្ថិតក្នុងការថែទាំពីឪពុកម្ដាយ ពួកគេទទួលសេវាថែទាំខាងក្រៅ ឬខាងក្នុង ដោយបុគ្គលិកជំនាញ ។

(ខ) សេវាថែទាំកុមារ រួមមានការពិនិត្យសុខភាពនៅពេលចូលពេទ្យ និងការបន្តតាមដានការអភិវឌ្ឍរបស់កុមារដោយមន្ត្រីជំនាញ។

២. កុមារនៅក្នុងពន្ធនាគារជាមួយឪពុកម្ដាយមិនត្រូវបានចាត់ទុកជាជនជាប់ឃុំទេ។

*វិធានទី៣០*

គ្រូពេទ្យ ឬមន្ត្រីជំនាញផ្នែកថែទាំសុខភាព ទោះជាត្រូវ ឬមិនតម្រូវឱ្យរាយការណ៍ជូនគ្រូពេទ្យ ក៏ត្រូវតែមើល ពិភាក្សា និងពិនិត្យជនជាប់ឃុំម្នាក់ៗឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីទទួលជនជាប់ឃុំចូលក្នុងពន្ធនាគារ និងពិនិត្យនាពេលក្រោយមកទៀតតាមតម្រូវការចាំបាច់។ ត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះ៖

(ក) ការកំណត់តម្រូវការការថែទាំសុខភាព និងការចាត់វិធានការចាំបាច់ទាំងអស់សម្រាប់ការព្យាបាល

(ខ) ការពិនិត្យមើលលក្ខណៈដែលស្ដែងចេញពីការធ្វើបាបផ្សេងៗមកលើជនជាប់ឃុំមុនពេលបញ្ជូនមកពន្ធនាគារ

(គ) ការកំណត់រោគសញ្ញាជំងឺផ្លូវចិត្ត ឬភាពតានតឹងផ្សេងដែលបណ្ដាលមកពីការជាប់ពន្ធនាគារ រួមមាន ហានិភ័យនៃការធ្វើអត្តឃាត ឬការបង្កអន្តរាយដល់ខ្លួនឯង និងរោគសញ្ញាផ្សេងៗដែលបណ្ដាលមកពីការសេពគ្រឿងញៀន ការប្រើឱសថ ឬគ្រឿងស្រវឹង និងបន្ទាប់មកត្រូវចាត់វាល់វិធានការ ឬការព្យាបាលជាក់ស្ដែងទៅតាមស្ថានភាពជនជាប់ឃុំម្នាក់ៗ។

(ឃ) ក្នុងករណីជនជាប់ឃុំសង្ស័យមានជំងឺឆ្លង ត្រូវរៀបចំដាក់ជនជាប់ឃុំដោយឡែក និងផ្តល់ការព្យាបាលត្រឹមត្រូវក្នុងអំឡុងពេលដែលមានជំងឺឆ្លង។

(ង) ការកំណត់ពីកាយសម្បទាជនជាប់ឃុំសម្រាប់ធ្វើការងារ លំហាត់ប្រាណ និងចូលរួមសកម្មភាពផ្សេងៗតាមលទ្ធភាពជាក់ស្តែង។

*វិធានទី៣១*

គ្រូពេទ្យ ឬមន្ត្រីជំនាញផ្នែកថែទាំសុខភាពត្រូវចូលទៅជួបជនជាប់ឃុំដែលឈឺជារៀងរាល់ថ្ងៃ ព្រមទាំងជួបជនជាប់ឃុំទាំងអស់ដែលបង្ហាញពីបញ្ហាសុខភាពផ្លូវកាយ ឬផ្លូវចិត្ត ឬរបួសស្នាម និងជនជាប់ឃុំណាដែលត្រូវមានការយកចិត្តទុកដាក់ជាពិសេស។ រាល់ការពិនិត្យផ្នែកវេជ្ជសាស្ត្រត្រូវធ្វើឡើងជាសម្ងាត់។

*វិធានទី៣២*

១. ទំនាក់ទំនងរវាងគ្រូពេទ្យឬមន្ត្រីជំនាញផ្នែកសុខភាពជាមួយនិងជនជាប់ឃុំ ត្រូវធ្វើឡើងស្របតាមក្រមសីលធម៌ និងបទដ្ឋានវិជ្ជាជីវៈ ដូចគ្នានឹងបទដ្ឋានដែលបានអនុវត្តចំពោះអ្នកជំងឺនៅក្នុងសហគមន៍ដូច្នោះដែរ ហើយជាពិសេស៖

(ក) កិច្ចការការពារសុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្តរបស់ជនជាប់ឃុំ និងការបង្ការ និងព្យាបាលជំងឺដែលត្រូវផ្អែកលើមូលដ្ឋានវេជ្ជាសាស្ត្រប៉ុណ្ណោះ

(ខ) ការប្រកាន់ខ្ជាប់ស្វ័យភាពរបស់ជនជាប់ឃុំចំពោះសុខភាពផ្ទាល់ខ្លួន និងការយល់ព្រមបន្ទាប់ពីទទួលបានព័ត៌មានគ្រប់គ្រាន់នៅអំឡុងពេលនៃការធ្វើទំនាក់ទំនងរវាងគ្រូពេទ្យ និងអ្នកជំងឺ

(គ) ការមានការសម្ងាត់វិជ្ជាជីវៈ វៀរលែងតែការមានការសម្ងាត់នោះបណ្តាលឱ្យមានការគំរាមកំហែងជាក់ស្តែង និងពិតប្រាកដចំពោះអ្នកជំងឺ ឬអ្នកដទៃ

(ឃ) ការហាមឃាត់ដាច់ខាតការចូលរួមសកម្មឬបែបអកម្មក្នុងអំពើណាមួយដែលអាជាទារុណកម្ម និងអំពើឃោរឃៅផ្សេងៗ អំពើអមនុស្សធម៌ ឬអំពើបន្ថោកបន្ទាប ឬទណ្ឌកម្ម រួមមានការពិសោធវេជ្ជសាស្ត្រ ឬវិទ្យាសាស្ត្រ ដែលអាចបណ្តាលឱ្យគ្រោះថ្នាក់ដល់សុខភាពជនជាប់ឃុំ ដូចជាកាត់យកកោសិកា ជាលិកា ឬសរីរាង្គរបស់ជនជាប់ឃុំជាដើម។

២. ដោយមិនប៉ះពាល់ដល់កថាខ័ណ្ឌទី ១ (ឃ) នៃវិធាននេះ ផ្អែកលើការយល់ព្រមដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់គ្រាន់ និងស្របតាមច្បាប់ជាធរមាន ជនជាប់ឃុំអាចអនុញ្ញាតចូលរួមក្នុងការពិសោធការព្យាបាល និងការស្រាវជ្រាវសុខភាពផ្សេងៗ នៅក្នុងសហគមន៍ ប្រសិនបើការពិសោធន៍ និងការស្រាវជ្រាវទាំងនេះរំពឹងថានឹងផ្តល់ផលប្រយោជន៍ផ្ទាល់ និងសំខាន់ចំពោះសុខភាពរបស់ពួកគេ និងអាចចូលរួមផ្តល់កោសិកា ជាលិកា ឬសរីរាង្គដល់សាច់ញាតិរបស់ជនជាប់ឃុំនោះ។

*វិធានទី៣៣*

គ្រូពេទ្យ ត្រូវរាយការណ៍ជូនប្រធានពន្ធនាគារនៅពេលណាខ្លួនបានដឹងថា សុខភាពផ្លូវកាយ ឬផ្លូវចិត្តរបស់ជនជាប់ឃុំបានទទួលរង ឬនឹងទទួលរងរបួសធ្ងន់ធ្ងរបណ្តាលមកពីការនៅក្នុងពន្ធនាគារ ឬលក្ខខណ្ឌណាមួយនៃការរស់នៅក្នុងពន្ធនាគារ។

*វិធានទី៣៤*

ក្នុងអំឡុងពេលពិនិត្យជនជាប់ឃុំ ពេលបញ្ជូនមកដល់ពន្ធនាគារ ឬក្នុងពេលផ្តល់ការថែទាំព្យាបាលនៅពេលបន្ទាប់មកទៀត ប្រសិនបើមន្ត្រីជំនាញវេជ្ជសាស្ត្រគ្រាប់តែដឹងពីសញ្ញានៃការធ្វើទារុណកម្ម ឬអំពើឃោរឃៅ អំពើអមនុស្សធម៌ ឬអំពើបន្ថោកបន្ទាប ឬទណ្ឌកម្ម ផ្សេងទៀត ពួកគេត្រូវចងក្រងជាឯកសារ និងរាយការណ៍ករណីនេះទៅអាជ្ញាធរសុខាភិបាល រដ្ឋបាល ឬតុលាការ។ ត្រូវអនុវត្តតាមនីតិវិធីការពារត្រឹមត្រូវដើម្បីការពារជនជាប់ឃុំ ឬបុគ្គលពាក់ព័ន្ធផ្សេងទៀតពីហានិភ័យនៃក្តីអន្តរាយដែលអាចមើលឃើញជាមុន។

*វិធានទី៣៥*

១. គ្រូពេទ្យ ឬស្ថាប័នសុខភិបាលសាធារណៈមានសមត្ថកិច្ចត្រូវពិនិត្យ និងប្រឹក្សាយោបល់ដល់ប្រធានពន្ធនាគារឱ្យបានទទៀតអំពី៖

(ក) បរិមាណ គុណភាព ការរៀបចំ និងសេវាអាហារ

(ខ) អនាម័យ និងភាពស្អាត របស់ស្ថាប័ន និងរបស់ជនជាប់ឃុំ

(គ) អនាម័យបរិស្ថាន សីតុណ្ហភាព ពន្លឺ និងខ្យល់ចេញចូលក្នុងពន្ធនាគារ

(ឃ) ភាពសមស្រប និងភាពស្អាតនៃសម្លៀកបំពាក់ និងកន្លែងដេករបស់ជនជាប់ឃុំ

(ង) ការគោរពតាមវិធាននានាទាក់ទងនឹងការអប់រំកាយ និងកីឡា ក្នុងករណីមិនមានអ្នកបច្ចេកទេសទទួលខុសត្រូវចំពោះសកម្មភាពទាំងនេះ។

២. ប្រធានពន្ធនាគារ ត្រូវពិចារណាលើដំបូន្មាន និងរបាយការណ៍ដែលបានផ្តល់ជូន ស្របតាមកថាខ័ណ្ឌទី ១ នៃវិធាននេះ និងវិធានទី៣៣ និងត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីអនុវត្តដំបូន្មាន និងអនុសាសន៍នានាដែលមានក្នុងរបាយការណ៍ទាំងនោះ។ ប្រសិនដំបូន្មាន ឬអនុសាសន៍ទាំងនោះមិនស្ថិតក្នុងដែនសមត្ថកិច្ចរបស់ប្រធានពន្ធនាគារ ឬប្រសិនគាត់មិនយល់ស្របជាមួយពួកគេ ប្រធានពន្ធនាគារត្រូវប្រគល់របាយរបស់គាត់ ដោយភ្ជាប់ជាមួយនឹងដំបូន្មាន និងអនុសាសន៍របស់គ្រូពេទ្យ ឬ របស់ស្ថាប័នសុខាភិបាលសាធារណៈ ទៅអាជ្ញាធរថ្នាក់លើរបស់ខ្លួនជាបន្ទាន់។

**ការរឹតបន្តឹង វិន័យ និងការដាក់ទណ្ឌកម្ម**

*វិធានទី៣៦*

ត្រូវប្រកាន់វិន័យ និងបញ្ជា មិនលើសពីកម្រិតនៃភាពចាំបាច់ ដើម្បីធានាសុវត្ថិភាពពន្ធនាគារ សន្តិសុខប្រតិបត្តិពន្ធនាគារ និងសណ្តាប់ធ្នាប់ល្អនៃការរស់នៅជាសមូហភាព។

*វិធានទី៣៧*

ប្រការខាងក្រោមត្រូវអនុវត្តស្របតាមការអនុញ្ញាតដែលមានចែងក្នុងច្បាប់ ឬបទបញ្ជាដែលចេញដោយអាជ្ញាធររដ្ឋបាលមានសមត្ថកិច្ចៈ

(ក) ការប្រព្រឹត្តណាដែលល្មើសនឹងវិន័យពន្ធនាគារ

(ខ) ប្រភេទ និងថេរវេលានៃទណ្ឌកម្មវិន័យដែលអាចមាន

(គ) អាជ្ញាធរមានសមត្ថកិច្ចក្នុងការដាក់ទណ្ឌកម្មវិន័យ

(ឃ) ទម្រង់ណាមួយនៃការបំបែកជនជាប់ឃុំចេញដោយមិនមានការស្ម័គ្រចិត្ត ដូចជាការដាក់ឃុំដាច់ដោយឡែក ការដាក់ឱ្យនៅដាច់ពីគេ ការបំបែក ការដាក់ក្រុមថែទាំពិសេស ឬការរឹតបន្តឹងការស្នាក់នៅដោយសារទណ្ឌកម្មវិន័យ ឬដោយសារមូលហេតុរក្សាសណ្តាប់ធ្នាប់ និងសន្តិសុខពន្ធនាគារ ព្រមទាំងការប្រកាសផ្សព្វផ្សាយអំពីគោលនយោបាយ និងនីតិវិធីគ្រប់គ្រងលើការប្រើប្រាស់និងការពិនិត្យឡើងវិញលើការចាត់ចែងនិងការបញ្ចប់វិធានការបំបែកដោយមិនមានការស្ម័គ្រចិត្តខាងលើ ។

*វិធានទី៣៨*

១. រដ្ឋបាលពន្ធនាគារត្រូវបានលើកទឹកចិត្ត ឱ្យប្រើប្រាស់ មួយផ្នែកនៃយន្តការបង្ការ សម្របសម្រួលជម្លោះ ឬយន្តការដោះស្រាយវិវាទផ្សេងៗទៀត ដើម្បីការពារការល្មើសវិន័យ ឬដោះស្រាយជម្លោះ។

២. ចំពោះជនជាប់ឃុំ ដែល ឬត្រូវបាននៅដាក់ឱ្យនៅដាច់ពីគេ រដ្ឋបាលពន្ធនាគារត្រូវចាត់វិធានការចាំបាច់នានា ដើម្បីសម្រាលផលប៉ះពាល់នៃការឃុំឃាំងទៅលើខ្លួនគេ និងទៅលើសហគមន៍របស់ពួកគេ បន្ទាប់ពីការដោះលែងចេញពីពន្ធនាគារ។

*វិធានទី៣៩*

១. គ្មានជនជាប់ឃុំណាម្នាក់ត្រូវទទួលទណ្ឌកម្មផ្សេងក្រៅពីទណ្ឌកម្មដែលមានចែងក្នុងច្បាប់ឬបទបញ្ញា ដូចមានយោងក្នុងវិធានទី៣៧ និងស្របតាមគោលការណ៍ស្មើភាព និងនីតិវិធីត្រឹមត្រូវ។ ជនជាប់ឃុំមិនត្រូវបានធ្វើទណ្ឌកម្មវិន័យពីរដងចំពោះអំពើឬបទល្មើសដដែលឡើយ។

២. រដ្ឋបាលពន្ធនាគារ ត្រូវធានាសមាមាត្ររវាងទណ្ឌកម្មវិន័យ និងការបំពានវិន័យ ដែលត្រូវបានប្រព្រឹត្តឡើង និងត្រូវរក្សាកំណត់ត្រាទណ្ឌកម្មវិន័យទាំងអស់ឱ្យបានត្រឹមត្រូវ។

៣. មុននឹងដាក់ទណ្ឌកម្មវិន័យ រដ្ឋបាលពន្ធនាគារ ត្រូវពិចារណាថាតើជំងឺផ្លូវចិត្ត ឬអសមត្ថភាពផ្នែកការអភិវឌ្ឍ អាចជាកត្តារួមចំណែកដល់ការប្រព្រឹត្តរបស់ពួកគេដែរឬទេ ឬរួមចំណែកដល់អំពើដែលបណ្តាលឱ្យមានការចោទប្រកាន់ផ្នែកវិន័យដែរឬទេ ហើយប្រសិនបើមានតើវាកើតឡើងដោយរបៀបណា។ រដ្ឋបាលពន្ធនាគារ មិនត្រូវដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តណាមួយរបស់ជនជាប់ឃុំ ដែលបណ្តាលមកពីជំងឺផ្លូវចិត្ត ឬអសមត្ថភាពផ្នែកបញ្ញារបស់គេឡើយ។

*វិធានទី៤០*

១. គ្មានជនជាប់ឃុំណាម្នាក់ត្រូវបានជួលធ្វើការងាររបស់ពន្ធនាគារ ក្រោមលក្ខខណ្ឌទណ្ឌកម្មវិន័យនោះទេ។

២. ទោះជាយ៉ាងណាក៏ដោយ វិធាននេះមិនត្រូវរារាំងដំណើរការប្រព្រឹត្តទៅរបស់ប្រព័ន្ធស្វ័យគ្រប់គ្រងដែលត្រូវបង្កើតឡើងតាមរយៈការចាត់តាំងជនជាប់ឃុំជាក្រុមក្រោមការគ្រប់គ្រងរបស់មន្ត្រីពន្ធនាគារដើម្បីចូលរួមសកម្មភាពសង្គម អប់រំកែប្រែ ឬសកម្មភាពកីឡាជាក់លាក់ ឬភារកិច្ចផ្សេងទៀត។

*វិធានទី៤១*

១. ការចោទប្រកាន់ពីបទល្មើសវិន័យទៅលើជនជាប់ឃុំណាម្នាក់ត្រូវរាយការណ៍ជាបន្ទាន់ទៅកាន់ស្ថាប័នមានសមត្ថកិច្ច ដែលត្រូវចាត់តាំងការស៊ើបអង្កេតដោយមិនបង្អង់យូរ។

២. ជនជាប់ឃុំត្រូវបានជូនដំណឹង ដោយមិនបង្អង់ និងក្នុងភាសាមួយដែលពួកអាចយល់បាន ពីប្រភេទនៃការចោទប្រកាន់ទៅលើពួកគេ និងត្រូវបានផ្តល់ពេលវេលា និង លទ្ធភាពគ្រប់គ្រាន់សម្រាប់ការរៀបចំការការពារក្តីរបស់ពួកគេ។

៣. ជនជាប់ឃុំត្រូវបានអនុញ្ញាតឱ្យការពារដោយខ្លួនឯង ឬតាមរយៈជំនួយផ្នែកច្បាប់ នៅពេលផលប្រយោជន៍យុត្តិធម៌មានការតម្រូវខ្លាំង ជាពិសេសក្នុងករណីបទចោទប្រកាន់ផ្នែកវិន័យកម្រិតធ្ងរ។ ប្រសិនជនជាប់ឃុំមិនយល់ ឬមិនចេះភាសាដែលប្រើនៅក្នុងសវនាការជំនុំជម្រះបទល្មើសវិន័យ ពួកគេត្រូវបានជំនួយពីអ្នកបកប្រែមានសមត្ថភាពគ្រប់គ្រាន់ដោយឥតគិតថ្លៃ។

៤. ជនជាប់ឃុំត្រូវមានឱកាសទទួលបានការជំនុំជម្រះឡើងវិញតាមផ្លូវតុលាការទៅលើទណ្ឌកម្មវិន័យដែលខ្លួនទទួលរង។

៥. ក្នុងករណីដែលការបំពានលើវិន័យត្រូវបានវិនិច្ឆ័យថាជាបទឧក្រិដ្ឋ ជនជាប់ឃុំមានសិទ្ធិទទួលបានការធានាផ្នែកនីតិវិធីត្រឹមត្រូវទាំងអស់ ដែលអនុវត្តចំពោះរឿងក្តីព្រហ្មទណ្ឌ រួមមានការទទួលជួបទីប្រឹក្សាច្បាប់ដោយគ្មានឧបសគ្គ។

*វិធានទី៤២*

លក្ខខណ្ឌរស់នៅទូទៅ ដែលបានរៀបរាប់ក្នុងវិធានទាំងនេះ រួមមានពន្លឺ ខ្យល់ចេញចូល សីតុណ្ហភាព ការដាក់ទណ្ឌកម្ម អាហារូបត្ថម្ភ ទឹកផឹក ការចេញទៅទទួលខ្យល់អាកាសខាងក្រៅ និងការហាត់ប្រាណ អនាម័យផ្ទាល់ខ្លួន ការថែទាំសុខភាព និងទីកន្លែងផ្ទាល់ខ្លួនសមរម្យ ត្រូវអនុវត្តចំពោះជនជាប់ឃុំទាំងអស់ដោយមិនរើសអើង។

*វិធានទី៤៣*

១. ទោះក្នុងស្ថានភាពណាក៏ដោយ ការរឹតបន្តឹង ឬការដាក់ទណ្ឌកម្មវិន័យមិនត្រូវធ្វើឡើងក្នុងន័យធ្វើទារុណកម្ម ឬអំពើឃោរឃៅ អំពើអមនុស្សធម៌ ឬអំពើបន្ថោកបន្ទាប ឬទណ្ឌកម្ម ផ្សេងទៀតឡើយ។ ជាពិសេស ទង្វើខាងក្រោមត្រូវបានហាមឃាត់៖

(ក) ការដាក់ឃុំខ្លួនដាច់តែឯងដោយមិនមានពេលកំណត់

(ខ) ការចេះតែបន្តដាក់ឃុំខ្លួនដាច់តែឯង

(គ) ការដាក់ជនជាប់ឃុំក្នុងបន្ទប់ងងឹត ឬបន្ទប់ភ្លឺចាំងរហូត

(ឃ) ការដាក់ទណ្ឌកម្មលើរាងកាយ ឬការកាត់បន្ថយរបបអាហារឬទឹក

(ង) ការដាក់ទណ្ឌកម្មជាសមូហភាព។

២. ឧបករណ៍ឃុំឃាំង មិនត្រូវបានប្រើប្រាស់ជាទណ្ឌកម្មចំពោះបទល្មើសវិន័យទេ។

៣. ទណ្ឌកម្មវិន័យ ឬវិធានការរឹតបន្តឹង មិនត្រូវរួមបញ្ចូលការហាមឃាត់មិនឱ្យមានទំនាក់ទំនងជាមួយគ្រួសារទេ។ មធ្យោបាយទំនាក់ទំនងជាមួយគ្រួសារអាចត្រូវបានរឹតត្បិតតែក្នុងរយៈពេលកំណត់ណាមួយ និងនៅពេលណាដែលតម្រូវឱ្យមានការធានាសន្តិសុខ និងសណ្តាប់ធ្នាប់ប៉ុណ្ណោះ។

*វិធានទី៤៤*

ចំពោះគោលបំណងនៃវិធានទាំងនេះ ការឃុំខ្លួនដាច់តែឯងគឺជាការឃុំឃាំងជនជាប់ឃុំចាប់ពីរយៈពេល ២២ ម៉ោង ឡើងទៅ ក្នុងមួយថ្ងៃ ដោយមិនឱ្យមានទំនាក់ទំនងចាំបាច់ជាមួយមនុស្សដទៃ។ ការបន្តឃុំខ្លួនដាច់តែឯងគឺជាការឃុំឃាំងតែម្នាក់ឯង សម្រាប់រយៈពេលលើសពី១៥ថ្ងៃជាប់ៗគ្នា។

*វិធានទី៤៥*

១. ការឃុំឃាំងតែម្នាក់ឯង ត្រូវបានអនុវត្តតែក្នុងករណីពិសេសនិងក្នុងដំណាក់កាលចុងក្រោយប៉ុណ្ណោះ សម្រាប់រយៈពេលខ្លីតាមអាចធ្វើបាន និងក្រោមការពិនិត្យឡើងវិញដោយឯករាជ្យ និងអនុលោមតាមការអនុញ្ញាតរបស់អាជ្ញាធរមានសមត្ថកិច្ច។ វាមិនត្រូវប្រើប្រាស់ដោយអាស្រ័យលើទោសរបស់ជនជាប់ឃុំម្នាក់ៗឡើយ។

២. ការដាក់ឃុំខ្លួនតែម្នាក់ឯង គួរត្រូវបានហាមឃាត់ ក្នុងករណីជនជាប់ឃុំមានពិការភាពផ្លូវចិត្ត ឬផ្លូវកាយ នៅពេលដែលពិការភាពនេះអាចនឹងកាន់តែធ្ងន់ធ្ងរដោយសារវិធានការនេះ។ ការហាមឃាត់ការប្រើប្រាស់ការឃុំខ្លួនតែម្នាក់ឯង និងវិធានាការស្រដៀងគ្នានេះ ចំពោះស្ត្រី និងកុមារ ដែលមានចែងក្នុងបទដ្ឋាន និងវិធានអង្គការសហប្រជាជាតិនានាស្តីពីការបង្ការឧក្រិដ្ឋកម្មនិងយុត្តិធម៌ព្រហ្មទណ្ឌនៅបន្តប្រើប្រាស់ដដែល។

*វិធានទី៤៦*

១. បុគ្គលិកថែទាំសុខភាព មិនត្រូវមានតួនាទីណាមួយនៅក្នុងការដាក់ទណ្ឌកម្មវិន័យ ឬវិធានការរឹត

បន្ទឹងផ្សេងទៀតឡើយ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេត្រូវយកចិត្តទុកដាក់ចំពោះសុខភាពរបស់ជនជាប់ឃុំ ដែលដាក់ក្នុងទម្រង់ណាមួយដាច់ដោយឡែកដោយអចេតនា រួមមានតាមរយៈការសួរសុខទុក្ខជនជាប់ឃុំប្រចាំថ្ងៃ និងការផ្តល់ជំនួយផ្នែកវេជ្ជសាស្ត្រ និងការព្យាបាលទាន់ពេលវេលា តាមសំណើរបស់ជនជាប់ឃុំ ឬមន្ត្រីពន្ធនាគារ។

២. បុគ្គលិកថែទាំងសុខភាព ត្រូវរាយការណ៍ជូនប្រធានពន្ធនាគារដោយមិនពន្យារពេល អំពីលទ្ធផលអវិជ្ជមាននៃទណ្ឌកម្មវិន័យ ឬ វិធានការរឹតបន្តឹងផ្សេងទៀតស្តីពីសុខភាពផ្លូវកាយ ឬសុខភាពផ្លូវចិត្តរបស់ជនជាប់ឃុំដែលទទួលរងពីទណ្ឌកម្មនេះ ឬពីវិធានការផ្សេងៗ និងត្រូវផ្តល់ដំបូន្មានដល់ប្រធានពន្ធនាគារ ប្រសិនពួកគេគិតថាចាំបាច់ ដើម្បីបញ្ឈប់ឬកែប្រែវិធានការទាំងនោះដោយសារមូលហេតុសុខភាពផ្លូវកាយ ឬសុខភាពផ្លូវចិត្ត។

៣. បុគ្គលិកថែទាំងសុខភាព ត្រូវមានសិទ្ធិអំណាចដើម្បីពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍ផ្លាស់ប្តូរការបំបែកជនជាប់ឃុំដោយមិនមានការស្ម័គ្រចិត្ត ដើម្បីធានាថាវិធានការដាក់បំបែកជនជាប់ឃុំមិនធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថានភាពសុខភាព ឬពិការភាពផ្នែករាងកាយឬផ្លូវចិត្តរបស់ជនជាប់ឃុំ។

**ឧបករណ៍ឃុំឃាំង**

*វិធានទី៤៧*

១. ការប្រើប្រាស់ច្រវាក់ ដែក ឬឧបករណ៍ឃុំឃាំងផ្សេងទៀត ដែលបន្ថោកបន្ទាប ឬបង្កការឈឺចាប់ជា ត្រូវបានហាមឃាត់។

២. ឧបករណ៍ឃុំឃាំងផ្សេងទៀត ត្រូវបានប្រើប្រាស់តែនៅពេលមានការអនុញ្ញាតដោយច្បាប់ និងក្នុងកាលៈទេសៈដូចខាងក្រោម៖

(ក) ដើម្បីបង្ការការលួចរត់ ក្នុងអំឡុងពេលផ្ទេរ ឬជនជាប់ឃុំត្រូវបានយកចេញពីពន្ធនាគារទៅបង្ហាញខ្លួនចំពោះមុខតុលាការ ឬអាជ្ញាធររដ្ឋបាល

(ខ) ដោយមានបញ្ជាពីប្រធានពន្ធនាគារ និងនៅពេលដែលវិធីសាស្ត្រផ្សេងទៀតមិនទទួលបានជោគជ័យក្នុងការការពារជនជាប់ឃុំពីការបង្ករបួសស្នាមលើខ្លួនឯងឬលើអ្នកដទៃ ឬការបំផ្លាញទ្រព្យសម្បត្តិ។ ក្នុងករណីនេះ ប្រធានពន្ធនាគារត្រូវជូនដំណឹងជាបន្ទាន់ដល់គ្រូពេទ្យ ឬមន្ត្រីជំនាញថែទាំសុខភាព និងរាយការណ៍ជូនអាជ្ញាធរថ្នាក់លើ។

*វិធានទី៤៨*

១. នៅពេលការដាក់ឱ្យប្រើប្រាស់ឧបករណ៍ឃុំឃាំង ដែលត្រូវបានអនុញ្ញាតស្របតាមកថាខ័ណ្ឌទី២ នៃវិធានទី៤៧ គេត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោមៈ

(ក) ឧបករណ៍ឃុំឃាំង ត្រូវបានប្រើប្រាស់ តែនៅពេលណាដែលវិធានការស្រាលជាងនេះមិនមានប្រសិទ្ធភាពក្នុងការដោះស្រាយហានិភ័យដែលអាចកើតមានដោយសារតែសកម្មភាពនោះមិនត្រូវបានរិតបន្តឹង

(ខ) របៀបប្រើប្រាស់ឧបករណ៍ឃុំឃាំងគួរតែធ្វើជាលក្ខណៈអប្បបរមា ដែលចាំបាច់ និងមានហេតុផលត្រឹមត្រូវ ដើម្បីគ្រប់គ្រងសកម្មភាពរបស់ជនជាប់ឃុំ ដោយផ្អែកលើកម្រិត និងប្រភេទនៃហានិភ័យដែលអាចកើតមានឡើង

(គ) ឧបករណ៍ឃុំឃាំង គួរត្រូវបានប្រើសម្រាប់តែក្នុងរយៈពេលចាំបាច់ប៉ុណ្ណោះ និងត្រូវបានដោះចេញវិញភ្លាមៗតាមដែលអាចធ្វើបាន បន្ទាប់ពីហានិភ័យដែលកើតឡើងដោយសារសកម្មភាពមិនរិតបន្តឹងទាំងនោះលែងមានតទៅទៀត។

២. ឧបករណ៍ឃុំឃាំង មិនត្រូវបានប្រើចំពោះស្ត្រី ក្នុងអំឡុងពេលមានគភ៌ អំឡុងពេលសម្រាលកូន និងបន្ទាប់ពីសម្រាលកូនរួចភ្លាម។

*វិធានទី៤៩*

រដ្ឋបាលពន្ធនាគារ ត្រូវស្វែងរក និងផ្តល់ការបណ្តុះបណ្តាលពីការប្រើប្រាស់ និងបច្ចេកទេសគ្រប់គ្រងឧបករណ៍ឃុំឃាំងដើម្បីបញ្ចៀសតម្រូវការប្រើប្រាស់វា ឬកាត់បន្ថយឥទ្ធិពលនៃឧបករណ៍ទាំងនោះ។

**ការឆែកឆេរជនជាប់ឃុំ និងបន្ទប់ឃុំឃាំង**

*វិធានទី៥០*

ច្បាប់ និងបទបញ្ញាសម្រាប់គ្រប់គ្រងការឆែកឆេរជនជាប់ឃុំ និងបន្ទប់ឃុំឃាំង ត្រូវអនុលោមតាមកាតព្វកិច្ចនានាក្រោមច្បាប់អន្តរជាតិ និងត្រូវគិតអំពីបទដ្ឋាន និងនិយាមអន្តរជាតិ និងត្រូវគិតគូរពីតម្រូវការធានាសន្តិសុខក្នុងពន្ធនាគារ។ ការឆែកឆេរត្រូវធ្វើឡើងតាមវិធីគោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស និងសិទ្ធិនៃជីវភាពឯកជនរបស់អ្នកដែលត្រូវឆែកឆេរនោះ ក៏ដូចជាគោលការណ៍ស្តីពីភាពសមាមាត្រ នីត្យានុកូលភាព និងភាពចាំបាច់។

*វិធានទី៥១*

ការឆែកឆេរមិនត្រូវបានប្រើដើម្បីបៀតបៀន បំភិតបំភ័យ ឬចូលទៅរំខានជីវិតឯកជនរបស់ជនជាប់ឃុំឡើយ។ ចំពោះគោលបំណងនៃគណនេយ្យភាពវិញ រដ្ឋបាលពន្ធនាគារត្រូវរក្សារបាយការណ៍ពិនិត្យនេះឱ្យបានត្រឹមត្រូវ ជាពិសេសការឆែកឆេរដោយមានការឱ្យដោះសម្លៀកបំពាក់ខាងក្រៅ និងការឆែកឆេររាងកាយ និងការឆែកឆេរបន្ទប់ឃុំឃាំង ដោយត្រូវកត់ត្រានូវមូលហេតុតម្រូវឱ្យមានការឆែកឆេរ អត្តសញ្ញាណអ្នកឆែកឆេរ និងលទ្ធផលនៃការឆែកឆេរ។

*វិធានទី៥២*

១. ការឆែកឆេរដែលប៉ះពាល់ដល់ឯកជនភាពដែលមានដូចជាឆែកឆេរដោយមានការឱ្យដោះសម្លៀកបំពាក់ខាងក្រៅ និងការឆែកឆេររាងកាយ អាចត្រូវបានធ្វើឡើងតែក្នុងករណីចាំបាច់ដាច់ខាតប៉ុណ្ណោះ។ រដ្ឋបាលពន្ធនាគារ ត្រូវបានលើកទឹកចិត្តដើម្បីបង្កើត និងប្រើប្រាស់ជម្រើសផ្សេងក្រៅពីការឆែកឆេរប្រភេទនេះ។ ការពិនិត្យដែលប៉ះពាល់ដល់ឯកជនភាព ត្រូវធ្វើឡើងជាឯកជន និងដោយបុគ្គលិកដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ និងដែលមានភេទដូចគ្នានឹងជនជាប់ឃុំ។

២. ការឆែកឆេររាងកាយ ត្រូវធ្វើឡើងដោយមន្ត្រីថែទាំសុខភាពជំនាញប៉ុណ្ណោះ មិនមែនដោយមន្ត្រីមានភារកិច្ចចម្បងក្នុងការថែទាំងជនជាប់ឃុំឡើយ ឬយ៉ាងហោចណាស់ដោយមន្ត្រីដែលទទួលការបណ្តុះបណ្តាលត្រឹមត្រូវដោយគ្រូពេទ្យលើផ្នែកបទដ្ឋានអនាម័យ សុខភាព និងសុវត្ថិភាព។

*វិធានទី៥៣*

ជនជាប់ឃុំត្រូវទទួលបានឯកសារទាក់ទងនឹងនីតិវិធីរឿងក្តីរបស់ពួកគេ ឬត្រូវបានអនុញ្ញាតឱ្យរក្សាទុកនូវឯកសារទាំងនោះដោយខ្លួនឯងដោយមិនចាំបាច់ឱ្យមន្ត្រីរដ្ឋបាលពន្ធនាគារមើលបាន។

**ព័ត៌មានសម្រាប់ជនជាប់ឃុំ និងបណ្តឹងរបស់ជនជាប់ឃុំ**

*វិធានទី៥៤*

នៅពេលទទួលចូលពន្ធនាគារ ជនជាប់ឃុំត្រូវបានព័ត៌មានជាលាយលក្ខណ៍អក្សរភ្លាមៗអំពី៖

(ក) ច្បាប់ស្តីពីពន្ធនាគារ និងបទបញ្ជាផ្ទៃក្នុងផ្សេងៗរបស់ពន្ធនាគារដែលកំពុងអនុវត្ត

(ខ) សិទ្ធិរបស់ពួកគេ រួមមានរបៀបស្វែងរកព័ត៌មានដែលត្រូវបានអនុញ្ញាត សិទ្ធិទទួលបានការប្រឹក្សាផ្នែកច្បាប់និងជំនួយផ្នែកច្បាប់ និងនីតិវិធីសម្រាប់ធ្វើសំណើ ឬបណ្តឹងតវ៉ា

(គ) កាតព្វកិច្ចរបស់ពួកគេ រួមទាំងទណ្ឌកម្មវិន័យដែលអាចអនុវត្តបាន និង

(ឃ) បញ្ហានានាដែលចាំបាច់ដើម្បីជួយជនជាប់ឃុំសម្របខ្លួនទៅនឹងជីវិតនៅក្នុងពន្ធនាគារ។

*វិធានទី៥៥*

១. ព័ត៌មានដែលបានរៀបរាប់នៅក្នុងវិធានទី៥៤ ត្រូវរកបានជាភាសាដែលនិយមប្រើបំផុត ស្របតាមតម្រូវការរបស់ជនជាប់ឃុំក្នុងពន្ធនាគារ។ ប្រសិនជនជាប់ឃុំមិនយល់ពីភាសាណាមួយ ត្រូវផ្តល់សេវាបកប្រែ។

២. ប្រសិនជនជាប់ឃុំមិនចេះអក្សរ ត្រូវផ្តល់ព័ត៌មានដល់ពួកគាត់ដោយផ្ទាល់មាត់។ ប្រសិនជនជាប់ឃុំពិការភាពផ្នែកញាណ ត្រូវផ្តល់ព័ត៌មានដល់ពួកគេតាមរយៈមធ្យោបាយសមស្របតាមតម្រូវការរបស់ពួកគេ។

៣. រដ្ឋបាលពន្ធនាគារ ត្រូវបិទបង្ហាញព័ត៌មានសង្ខេបក្នុងបរិវេណសាធារណៈរបស់ពន្ធនាគារ។

*វិធានទី៥៦*

១. រាល់ជនជាប់ឃុំ ក្នុងមួយថ្ងៃៗត្រូវមានឱកាសធ្វើសំណើ ឬបណ្តឹងទៅប្រធានពន្ធនាគារ ឬមន្ត្រីពន្ធនាគារដទៃទៀត ដែលទទួលសិទ្ធិតំណាង។

២. ជនជាប់ឃុំត្រូវមានឱកាសធ្វើសំណើឬប្តឹងទៅកាន់អធិការពន្ធនាគារក្នុងអំឡុងពេលអធិការកិច្ច។ ជនជាប់ឃុំត្រូវមានឱកាសនិយាយជាមួយអធិការពន្ធនាគារឬមន្ត្រីអធិការកិច្ចដោយសេរី និងដោយសម្ងាត់ ដោយមិនមានវត្តមានរបស់ប្រធានពន្ធនាគារឬមន្ត្រីពន្ធនាគារដទៃទៀត។

៣. រាល់ជនជាប់ឃុំត្រូវបានអនុញ្ញាតឱ្យធ្វើសំណើ ឬប្តឹងតវ៉ាចំពោះការប្រព្រឹត្តទៅលើពួកគេ ដោយគ្មានការត្រួតពិនិត្យ ទៅកាន់រដ្ឋបាលពន្ធនាគារកណ្តាល និងទៅកាន់អាជ្ញាធរតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត រួមមានអាជ្ញាធរមដែលមានសិទ្ធិត្រួតពិនិត្យ ឬមានអំណាចដោះស្រាយ។

៤. សិទ្ធិក្នុងកថាខ័ណ្ឌទី១ ដល់ទី៣ នៃវិធាននេះ ត្រូវបន្តផ្តល់ដល់ទីប្រឹក្សាច្បាប់របស់ជនជាប់ឃុំថែមទៀត។ ក្នុងករណីទាំងជនជាប់ឃុំ ឬទីប្រឹក្សាច្បាប់របស់ជនជាប់ឃុំ មិនអាចអនុវត្តសិទ្ធិទាំងនោះបាន

សមាជិកណាម្នាក់នៃគ្រួសាររបស់ជនជាប់ឃុំ ឬបុគ្គលផ្សេងទៀតដែលដឹងរឿងនេះ អាចអនុវត្តសិទ្ធិទាំងនេះបាន។

*វិធានទី៥៧*

១. រាល់សំណើនិងបណ្ដឹងតវ៉ាត្រូវបានដោះស្រាយនិងឆ្លើយតបជាបន្ទាន់ដោយមិនពន្យារពេល។ ប្រសិន សំណើ ឬបណ្ដឹងតវ៉ាត្រូវបានបដិសេធ ឬក្នុងករណីពន្យារពេលយូសហេតុពេក នោះអ្នកដាក់ពាក្យបណ្ដឹង មានសិទ្ធិនាំយកបណ្ដឹងនេះទៅចំពោះមុខអាជ្ញាធរតុលាការ ឬអាជ្ញាធរផ្សេងទៀត។

២. ត្រូវមានប្រព័ន្ធការពារនៅនឹងកន្លែង ដើម្បីធានាថាជនជាប់ឃុំអាចធ្វើសំណើ ឬដាក់ពាក្យប្ដឹងតវ៉ាដោយសុវត្ថិភាព និងដោយសម្ងាត់ប្រសិនបើអ្នកប្ដឹងតវ៉ាស្នើសុំ។ ជនជាប់ឃុំ ឬអ្នកផ្សេងដែលបានរៀបរាប់នៅក្នុងកថាខ័ណ្ឌទី៤ នៃវិធានទី៥៦ មិនត្រូវប្រឈមនឹងហានិភ័យទាក់ទងនឹងការសងសឹក ការគំរាមកំហែង ឬលទ្ធផលអវិជ្ជមានផ្សេងៗ ដែលបណ្ដាលមកពីការដាក់សំណើ ឬការប្ដឹងតវ៉ានោះ។

៣. ការចោទប្រកាន់ថាមានការធ្វើទារុណកម្ម ឬអំពើឃោរឃៅ អំពើអមនុស្សធម៌ ឬអំពើបន្ថោកបន្ទាប ឬទណ្ឌកម្ម ផ្សេងទៀត មកលើជនជាប់ឃុំ ត្រូវបានដោះស្រាយជាបន្ទាន់ និងធ្វើការស៊ើបអង្កេតភ្លាមៗ ដោយមិនលំអៀង ដោយអាជ្ញាធរជាតិឯករាជ្យមួយ ស្របតាមកថាខ័ណ្ឌទី១ដល់ទី២ នៃវិធានទី៧១។

ការទំនាក់ទំនងជាមួយពិភពខាងក្រៅ

*វិធានទី៥៨*

១. ក្រោមការឃ្លាំមើលក្នុងករណីចាំបាច់ ជនជាប់ឃុំត្រូវបានអនុញ្ញាតឱ្យមានទំនាក់ទំនងជាមួយគ្រួសារ និងមិត្តភក្ដិរបស់ពួកគេនៅចន្លោះពេលទៀងទាត់៖

(ក) តាមរយៈលិខិតឆ្លើយឆ្លង និងតាមរយៈមធ្យោបាយទូរគមនាគមន៍ អេឡិចត្រូនិច ឌីជីថល និងតាមរយៈមធ្យបាយផ្សេងទៀត ប្រសិនបើមាន និង

(ខ) តាមរយៈការសួរសុខទុក្ខ។

២. ក្នុងករណីមានការអនុញ្ញាតឱ្យមានការសួរសុខទុក្ខក្នុងឋានៈជាប្ដី-ប្រពន្ធ សិទ្ធិនេះត្រូវបានអនុវត្តដោយគ្មានការរើសអើង ហើយស្ត្រីជាជនជាប់ឃុំត្រូវប្រើសិទ្ធិនេះស្មើនឹងបុរសដែរ។ ត្រូវមាននីតិវិធីគ្រប់គ្រាន់ និងមានទីកន្លែងដើម្បីធានាការទទួលបានសុវត្ថិភាព និងសេចក្ដីថ្លៃថ្នូរ ដោយយុត្តិធម៌ និងស្មើភាពគ្នា។

*វិធានទី៥៩*

តាមទំហំលទ្ធភាព ត្រូវដាក់ជនជាប់ឃុំក្នុងពន្ធនាគាដែលនៅជិតផ្ទះ ឬនៅជិតទីកន្លែងស្តារនីតិសម្បទាផ្នែកសង្គមរបស់ជនជាប់ឃុំ។

*វិធានទី៦០*

១. ការអនុញ្ញាតឱ្យអ្នកសួរសុខទុក្ខចូលពន្ធនាគារគឺអាស្រ័យលើការយល់ព្រមរបស់អ្នកសួរសុខទុក្ខចំពោះការឆែកឆេរ។ អ្នកសួរសុខទុក្ខអាចដកការយល់ព្រមរបស់គេចេញបានគ្រប់ពេលវេលា ហើយជាលទ្ធផលរដ្ឋបាលពន្ធនាគារក៏អាចបដិសេធមិនឱ្យចូលសួរសុខទុក្ខជនជាប់ឃុំដែរ។

២. ការឆែកឆេរ និងនីតិវិធីចូលពន្ធនាគារសម្រាប់អ្នកសួរសុខទុក្ខគឺមិនត្រូវធ្វើឡើងក្នុងលក្ខណៈបន្ថោកបន្ទាបទេ និងត្រូវបានគ្រប់គ្រងដោយគោលការណ៍ការពារយ៉ាងហោចណាស់ ដូចដែលបានរៀបរាប់នៅក្នុងវិធានទី៥០ ដល់៥២។ ការឆែកឆេររាងកាយគួរត្រូវបានចៀសវាង និងមិនត្រូវអនុវត្តចំពោះកុមារទេ។

*វិធានទី៦១*

១. ជនជាប់ឃុំត្រូវបានផ្តល់ឱកាស ពេលវេលា និងសម្ភារៈបរិក្ខារគ្រប់គ្រាន់ដើម្បីដើរមើល និងទំនាក់ទំនង និងពិគ្រោះជាមួយទីប្រឹក្សាច្បាប់តាមការជ្រើសរើសរបស់ពួកគេ ឬអ្នកផ្តល់ជំនួយផ្នែកច្បាប់ ដោយគ្មានការពន្យារ ការលួចស្តាប់ ឬការត្រួតពិនិត្យយល់ព្រមជាមុនឡើយ និងស្ថិតក្នុងភាពការសម្ងាត់ពេញលេញស្របតាមច្បាប់ក្នុងស្រុក។ ការពិគ្រោះយោបល់គឺធ្វើនៅទីណាដែលមន្ត្រីពន្ធនាគារអាចមើលឃើញ ប៉ុន្តែស្តាប់មិនឮ។

២. ក្នុងករណីជនជាប់ឃុំមិនចេះភាសាក្នុងស្រុក រដ្ឋបាលពន្ធនាគារត្រូវសម្រួលការទទួលបានសេវាបកប្រែដែលមានគុណភាពនិងមានលក្ខណៈឯករាជ្យ។

៣. ជនជាប់ឃុំត្រូវទទួលបានជំនួយផ្នែកច្បាប់ប្រកបដោយប្រសិទ្ធភាព។

*វិធាន ៦២*

១. ជនជាប់ឃុំដែលជាជនបរទេស ត្រូវតែបានអនុញ្ញាតិតាមមធ្យោបាយណាមួយដែលសមរម្យដើម្បីទាក់ទងជាមួយអ្នកតំណាងទូត ឬកុងស៊ុលតំណាងប្រទេសរបស់គេ។

២. ចំពោះជនជាប់ឃុំជាជនបរទេស ដែលគ្មានតំណាងទូត ឬកុងស៊ុលប្រចាំនៅក្នុងប្រទេស ដែលកំពុងឃុំឃាំងខ្លួនទេនោះ ឬក៏ជនជាប់ឃុំនោះជាជនភៀសខ្លួន ឬជាជនដែលគ្មានប្រទេស ត្រូវតែបានអនុ

ញ្ញាតិតាមមធ្យោបាយណាមួយដែលសមរម្យ ដើម្បីឲ្យទាក់ទងជាមួយអ្នកតំណាងទូតនៃប្រទេស ដែលទទួលខុសត្រូវចំពោះផលប្រយោជន៍របស់ពួកគេ, ឬក៏ឲ្យទាក់ទងជាមួយអាជ្ញាធរជាតិឬអន្តរជាតិណាមួយដែលគេមានភារកិច្ចការពារជនជាប់ឃុំទាំងនោះ។

*វិធាន ៦៣*

ត្រូវអនុញ្ញាតឲ្យជនជាប់ឃុំបានទទួលដំណឹង ឬព័ត៌មានសំខាន់ៗយ៉ាងទៀងទាត់ ពោលគឺត្រូវអនុញ្ញាតឲ្យជនជាប់ឃុំអានកាសែត អានសៀវភៅ ឬអត្ថបទផ្សព្វផ្សាយ ឬស្តាប់ព័ត៌មានបច្ចេកវិជ្ជាទូរគមនាគមន៍ឥតខ្សែ ឬស្តាប់បាឋកថា ឬមធ្យោបាយនានា ដែលអនុញ្ញាតឬគ្រប់គ្រងដោយរដ្ឋបាលពន្ធនាគារ។

## សៀវភៅ

*វិធាន ៦៤*

គ្រប់ពន្ធនាគារទាំងអស់ត្រូវមានបណ្ណាល័យ សម្រាប់សេចក្តីត្រូវការរបស់ជនជាប់ឃុំគ្រប់ប្រភេទ។ ត្រូវមានសៀវភៅច្រើនបរិបូណ៌ ទាំងសៀវភៅផ្នែកកំសាន្ត និងសៀវភៅសិក្សា ហើយត្រូវណែនាំជនជាប់ឃុំទាំងអស់ឲ្យអានសៀវភៅឲ្យបានច្រើនបំផុត។

## សាសនា

*វិធាន ៦៥*

១. ប្រសិនបើនៅក្នុងពន្ធនាគារណាមួយ មានជនជាប់ឃុំដែលគោរពសាសនាដូចគ្នាច្រើនគ្រប់គ្រាន់ត្រូវតែងតាំងឬយល់ព្រមឲ្យមានតំណាងសាសនាដែលមានគុណសម្បត្តិគ្រប់គ្រាន់ម្នាក់សម្រាប់សេចក្តីត្រូវការរបស់ជនជាប់ឃុំទាំងនោះ។ ប្រសិនបើកាលៈទេសៈតម្រូវនិងអនុលោមតាមចំនួនជនជាប់ឃុំផងនោះ ការចាត់ចែងខាងលើត្រូវធ្វើឡើងក្នុងលក្ខណៈពេញម៉ោង។

២. អ្នកតំណាងសាសនាដែលត្រូវបានតែងតាំងឬយល់ព្រមស្របតាមកថាខណ្ឌ ១ ខាងលើ ត្រូវបានអនុញ្ញាតឱ្យធ្វើការបានទៀងទាត់ និងជួយប្រៀនប្រដៅជនជាប់ឃុំតាមមាគ៌ាសាសនារបស់ជនជាប់ឃុំទៅតាមពេលវេលាដ៏សមគួរ។

៣. មិនត្រូវហាមឃាត់ជនជាប់ឃុំមិនឲ្យជួបអ្នកតំណាងសាសនារបស់ពួកគេឡើយ។ ផ្ទុយទៅវិញ ប្រសិនបើជនជាប់ឃុំណាម្នាក់ពុំមានឆន្ទៈចង់ជួបអ្នកតំណាងសាសនាទេ នោះគេត្រូវគោរពតាមឆន្ទៈរបស់ជនជាប់ឃុំជានិច្ច។

*វិធាន ៦៦*

បើអាចអនុវត្តទៅបាន ជនជាប់ឃុំគ្រប់រូបត្រូវតែបានអនុញ្ញាតិ ដើម្បីបំពេញនូវសេចក្តីត្រូវការនៃជីវិតខាងផ្លូវសាសនារបស់គេតាមរយៈការចូលរួមក្នុងពិធីផ្សេងៗ ដែលអនុញ្ញាតិឲ្យមាននៅក្នុងពន្ធនាគារ និងអនុញ្ញាតិឲ្យរក្សាទុកនូវឯកសារ ឬ សៀវភៅនានាដែលស្តីពីការប្រៀនប្រដៅ និងការគោរពបូជាតាមមាគ៌ានៃនិកាយសាសនារបស់គេ។

**ការរក្សាទុកទ្រព្យសម្បត្តិផ្ទាល់របស់ជនជាប់ឃុំ**

*វិធាន ៦៧*

១. នៅដែលជនជាប់ឃុំចូលមកដល់ពន្ធនាគារភ្លាម ប្រាក់កាស គ្រឿងអលង្ការ សម្លៀកបំពាក់ និងសម្ភារៈផ្សេងៗទៀតដែលត្រូវហាមឃាត់ដោយបទបញ្ជាផ្ទៃក្នុងពន្ធនាគារ ត្រូវដកហូតហើយរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព។ ត្រូវឲ្យជនជាប់ឃុំចុះហត្ថលេខាលើបញ្ជីទ្រព្យសម្បត្តិ និងត្រូវចាត់វិធានការចាំបាច់នានា ដើម្បីរក្សាទុកដាក់ទ្រព្យទាំងនោះឲ្យបានគង់វង់។

២. ដល់ថ្ងៃដែលជនជាប់ឃុំចេញពីពន្ធនាគារ ទ្រព្យសម្បត្តិនិងប្រាក់កាស ត្រូវតែប្រគល់ឲ្យទៅម្ចាស់គេវិញទាំងអស់ លើកលែងតែប្រាក់កាសទាំងនោះកន្លងមកត្រូវបានគេអនុញ្ញាតិឲ្យចាយវាយអស់ ឬទ្រព្យសម្បត្តិទាំងនោះត្រូវបានផ្ញើទៅក្រៅពន្ធនាគារ ឬក៏សម្លៀកបំពាក់ខ្លះដែលគេយល់ឃើញថាជាចាំបាច់ត្រូវតែកំទេចចោលដោយសារហេតុផលអនាម័យ។ ជនជាប់ឃុំត្រូវចុះហត្ថលេខាលើលិខិតប្រគល់ទ្រព្យសម្បត្តិ និងប្រាក់កាសទាំងនោះ។

៣. ប្រាក់កាស ឬឥវ៉ាន់ទាំងឡាយណា ដែលបានទទួលមកពីខាងក្រៅសម្រាប់ជនជាប់ឃុំ ត្រូវតែធ្វើដូចគ្នាទៅនឹងករណីខាងលើដែរ។

៤. ប្រសិនបើជនជាប់ឃុំណាម្នាក់មានថ្នាំសង្កូវជាប់មកជាមួយ គ្រូពេទ្យត្រូវសម្រេចថាតើថ្នាំណាខ្លះដែលអាចអនុញ្ញាតឲ្យប្រើបាន ។

**ការជូនដំណឹង**

វិធានទី៦៨

រាល់ជនជាប់ឃុំម្នាក់ៗ មានសិទ្ធិ និងត្រូវបានផ្តល់លទ្ធភាព និងមធ្យោបាយ ដើម្បីផ្តល់ដំណឹងដល់គ្រួសាររបស់ពួកគេ អ្នកផ្សេងទៀតដែលអាចធ្វើទំនាក់ទំនងបាន អំពីការជាប់ពន្ធនាគាររបស់ពួកគេ អំពីការផ្ទេរទៅស្ថាប័នផ្សេង និងអំពីជំងឺ ឬរបួសធ្ងន់ធ្ងរ។ ការចែករំលែកព័ត៌មានផ្ទាល់ខ្លួនរបស់ជនជាប់ឃុំ ត្រូវគោរពតាមច្បាប់ក្នុងស្រុក។

វិធានទី៦៩

ក្នុងករណីជនជាប់ឃុំស្លាប់ ប្រធានពន្ធនាគារត្រូវជូនដំណឹងជាបន្ទាន់ដល់សាច់ញាតិរបស់ជនជាប់ឃុំ ឬអ្នកទំនាក់ទំនងសម្រាប់ករណីបន្ទាន់។ ប្រធានពន្ធនាគារត្រូវផ្តល់ដំណឹងទៅបុគ្គលដែលត្រូវបានជ្រើសរើសដោយជនជាប់ឃុំសម្រាប់ទទួលព័ត៌មានសុខភាពក្នុងករណីមានជំងឺធ្ងន់ធ្ងរ របួស ឬការផ្ទេរទៅស្ថាប័នព្យាបាលផ្នែកសុខភាពណាមួយ។ សំណើច្បាស់លាស់របស់ជនជាប់ឃុំ ដែលស្នើសុំមិនផ្តល់ព័ត៌មានដល់សហព័ទ្ធឬសាច់ញាតិជិតបំផុតទាក់ទងនឹងជំងឺឬរបួសរបស់ខ្លួនត្រូវតែគោរពតាម។

*វិធានទី៧០*

រដ្ឋបាលពន្ធនាគារត្រូវជូនដំណឹងជនជាប់ឃុំម្នាក់ជាបន្ទាន់អំពីជំងឺធ្ងន់ធ្ងរ ឬមរណភាពរបស់សាច់ញាតិជិតស្និទ្ធ ឬបុគ្គលសំខាន់ណាម្នាក់។ ពេលណាក៏ដោយដែលកាលៈទេសៈអំណោយផល ជនជាប់ឃុំត្រូវបានផ្តល់សិទ្ធិចូលទៅក្បែរខ្លួនសាច់ញាតិជិតស្និទ្ធ ឬបុគ្គលសំខាន់ ដែលមានជំងឺជាទម្ងន់ ឬទៅចូលរួមបុណ្យសពសាច់ញាតិជិតស្និទ្ធ ឬបុគ្គលសំខាន់នោះ។

**ការស៊ើបអង្កេត**

*វិធានទី៧១*

១. ថ្វីបើមានការចាប់ផ្តើមការស៊ើបអង្កេតផ្ទៃក្នុងក៏ដោយ ប្រធានពន្ធនាគារត្រូវរាយការណ៍ជាបន្ទាន់ដោយមិនបង្អង់អំពីករណីស្លាប់ក្នុងពន្ធនាគារ ការបាត់ខ្លួន ឬរបួសធ្ងន់ធ្ងរ ជូនអាជ្ញាធរតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតដែលឯករាជ្យដាច់ចេញពីរដ្ឋបាលពន្ធនាគារ ហើយដែលមានសមត្ថកិច្ចធ្វើការស៊ើបអង្កេតភ្លាមៗ មិនលម្អៀង និងមានប្រសិទ្ធភាពលើកាលៈទេសៈ និងមូលហេតុនៃករណីទាំងនោះ។ រដ្ឋបាលពន្ធនាគារ ត្រូវសហការពេញលេញជាមួយអាជ្ញាធរទាំងនោះ និងធានារក្សាភ័ស្តុតាងឱ្យបានត្រឹមត្រូវ។

២. កាតព្វកិច្ចក្នុងកថាខ័ណ្ឌទី១នៃវិធាននេះ ត្រូវអនុវត្តដូចគ្នាផងដែរចំពោះករណីមានមូលហេតុត្រឹមត្រូវដើម្បីជឿថាមានការកើតឡើងនូវអំពើទារុណកម្ម ឬអំពើឃោរឃៅ អំពើអមនុស្សធម៌ ឬអំពើបន្ថោកបន្ទាប ឬទណ្ឌកម្ម ផ្សេងទៀត ដែលបានប្រព្រឹត្តនៅក្នុងពន្ធនាគារ ដោយមិនចាំបាច់រង់ចាំទទួលពាក្យបណ្តឹងឡើយ។

៣. ពេលមានមូលហេតុត្រឹមត្រូវដើម្បីជឿថាអំពើមួយ ដូចដែលបានរៀបរាប់នៅក្នុងកថាខ័ណ្ឌទី២នៃវិធាននេះ ត្រូវបានប្រព្រឹត្ត ត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីធានាថាមនុស្សដែលមានការពាក់ព័ន្ធទាំងអស់ មិនមានជាប់ពាក់ព័ន្ធក្នុងការស៊ើបអង្កេត និងមិនអាចធ្វើទំនាក់ទំនងជាមួយសាក្សី ជនរងគ្រោះ ឬគ្រួសាររបស់ជនរងគ្រោះឡើយ។

*វិធានទី៧២*

រដ្ឋបាលពន្ធនាគារត្រូវទុកដាក់សពជនជាប់ឃុំដោយក្តីគោរព និងភាពថ្លៃថ្នូរ។ ត្រូវបញ្ជូនសពជនជាប់ឃុំទៅសាច់ញាតិឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ឬបន្ទាប់ពីការបិទបញ្ចប់ការស៊ើបអង្កេតភ្លាម។ រដ្ឋបាលពន្ធនាគារ ត្រូវសម្រួលដល់ការរៀបចំបុណ្យសពតាមប្រពៃណី ប្រសិនមិនមានភាគីណាមួយស្ម័គ្រចិត្តទទួលខុសត្រូវ ឬអាចរៀបចំធ្វើបាននោះទេ និងត្រូវរក្សាទុកកំណត់ហេតុនៃការរៀបចំទាំងនេះ។

## ការយកជនជាប់ឃុំចេញទៅក្រៅពន្ធនាគារ

*វិធាន ៧៣*

១. នៅពេលដែលជនជាប់ឃុំត្រូវបានយកចេញទៅឬពីស្ថាប័នមួយ ត្រូវចាត់ចែងពួកគេបញ្ចៀសឱ្យសាធារណជនបានឃើញជនជាប់ឃុំតិចតួចបំផុតតាមតែអាចធ្វើទៅបាន ហើយត្រូវការពារពួកគេពីការប្រមាថ ការចង់ឃើញចង់ដឹង និងការផ្សព្វផ្សាយគ្រប់រូបភាព។

២. ត្រូវហាមឃាត់ការដឹកជញ្ជូនជនជាប់ឃុំតាមរយៈមធ្យោបាយដែលមិនមានខ្យល់ឬពន្លឺគ្រប់គ្រាន់ឬធ្វើឲ្យពួកគេមានការលំបាកផ្នែករាងកាយដោយគ្មានហេតុផលចាំបាច់។

៣. ការដឹកជញ្ជូនជនជាប់ឃុំជាបន្ទុកចំណាយរបស់រដ្ឋបាលពន្ធនាគារ ហើយត្រូវធ្វើឡើងក្នុងលក្ខខណ្ឌស្មើភាពគ្នាចំពោះជនជាប់ឃុំគ្រប់រូប។

## មន្ត្រីធ្វើការឱ្យស្ថាប័នពន្ធនាគារ

*វិធាន ៧៤*

១. រដ្ឋបាលពន្ធនាគារត្រូវធ្វើការជ្រើសរើសមន្ត្រីពន្ធនាគារគ្រប់ថ្នាក់ដោយប្រុងប្រយ័ត្នដោយផ្អែកលើសុចរិតភាព អកប្បកិរិយាមនុស្សធម៌ សមត្ថភាពជំនាញ និងលក្ខណៈសម្បត្តិផ្ទាល់ខ្លួនសម្រាប់តម្រូវការ

គ្រប់គ្រងការងារពន្ធនាគារបានត្រឹមត្រូវ។

២. រដ្ឋបាលពន្ធនាគារត្រូវស្វែងរកការជាស់តឿនឥតឈប់ឈរនិងរក្សាការគិតរបស់មន្ត្រីពន្ធនាគារ និងសាធារណជនចំពោះការងារពន្ធនាគារដែលជាផ្នែកមួយនៃសេវាសង្គមដ៏មានសារៈសំខាន់បំផុត។ ក្នុងន័យនេះ មធ្យោបាយជូនដំណឹងសមស្របទាំងអស់ជូណសាធារណជនគួរតែត្រូវបានប្រើប្រាស់។

៣. ដើម្បីសម្រេចបានគោលដៅនេះ មន្ត្រីពន្ធនាគារត្រូវបានតែងតាំងឱ្យធ្វើការដោយផ្អែកលើមូលដ្ឋានពេញម៉ោងក្នុងក្របខ័ណ្ឌជាមន្ត្រីវិជ្ជាជីវៈសាធារណៈនិងមានស្ថេរភាពការងារគ្រប់គ្រាន់ឆ្លងកាត់ការវាយតម្លៃលើអាកប្បកិរិយាបំពេញការងារ ប្រសិទ្ធភាពការងារ និងកាយសម្បទា។ ប្រាក់បៀវត្សរ៍នឹងត្រូវបានគ្រប់គ្រាន់ដើម្បីរក្សាឱ្យមានចំនួនមន្ត្រីបុរសនិងស្ត្រី ហើយផលប្រយោជន៍ការងារនិងលក្ខខណ្ឌនៃសេវានឹងត្រូវឆ្លើយតបទៅតាមប្រភេទនៃការងារ។

*វិធានទី៧៥*

១. មន្ត្រីពន្ធនាគារទាំងអស់ត្រូវមានបទដ្ឋានអប់រំគ្រប់គ្រាន់ និងត្រូវបានប្រគល់លទ្ធភាព និងមធ្យោបាយនានា ដើម្បីអនុវត្តភារកិច្ចរបស់ពួកគេប្រកបដោយជំនាញវិជ្ជាជីវៈ។

២. មុនអនុវត្តភារកិច្ច មន្ត្រីពន្ធនាគារទាំងអស់ ត្រូវទទួលបានការបណ្តុះបណ្តាល ដើម្បីអនុវត្តកិច្ចការជាក់លាក់ និងកិច្ចការទូទៅ ដែលជាការឆ្លុះបញ្ចាំងពីបទពិសោធនិងគំរូជាក់ស្តែងល្អៗក្នុងផ្នែកវិទ្យាសាស្ត្រព្រហ្មទណ្ឌ។ មានតែបេក្ខជនដែលប្រឡងជាប់ដោយជោគជ័យផ្នែកទ្រឹស្តី និងការអនុវត្តនៅចុងបញ្ចប់វគ្គទេ ដែលត្រូវបានអនុញ្ញាតបម្រើសេវាពន្ធនាគារ។

៣. រដ្ឋបាលពន្ធនាគារ ត្រូវធានាថា ការបន្តវគ្គបំប៉នក្នុងគោលបំណងរក្សា និងកែលម្អចំណេះដឹង និងសមត្ថភាពវិជ្ជាជីវៈរបស់បុគ្គលិករបស់ខ្លួន បន្ទាប់ពីចូលបម្រើការងារ និងក្នុងអំឡុងពេលធ្វើការងារ។

*វិធានទី៧៦*

១. ការបណ្តុះបណ្តាលដែលបានរៀបរាប់នៅក្នុងកថាខ័ណ្ឌទី២ នៃវិធានទី៧៥ ត្រូវបញ្ចូល ជាអប្បបរមានូវប្រធានបទដូចខាងក្រោម៖

(ក) ច្បាប់ វិធាន និងគោលនយោបាយជាតិដែលទាក់ទង ក៏ដូចជា លិខិតុបករណ៍ថ្នាក់តំបន់ និងអន្តរជាតិដែលអាចអនុវត្តបាន និង បទប្បញ្ញត្តិនានា ដែលណែនាំការងារ និងទំនាក់ទំនងអន្តរកម្មរបស់មន្ត្រីពន្ធនាគារជាមួយទណ្ឌិត។

(ខ) សិទ្ធិ និងករណីយកិច្ចរបស់មន្ត្រីពន្ធនាគារ ក្នុងការអនុវត្តតួនាទីរបស់ពួកគេ រួមមាន ការគោរពសេចក្តីថ្លៃថ្នូររបស់ជនជាប់ឃុំគ្រប់រូប និងការហាមឃាត់ការប្រព្រឹត្តជាក់លាក់ ជាពិសេស ការធ្វើទារុណកម្ម និងអំពើឃោរឃៅ អំពើអមនុស្សធម៌ ឬអំពើបន្ថោកបន្ទាប ឬទណ្ឌកម្ម ផ្សេងទៀត។

(គ)	សន្តិសុខ និងសុវត្ថិភាព រួមមានគោលការណ៍សន្តិសុខចលករ ការប្រើកម្លាំង និងឧបករណ៍ឃុំឃាំង និងការគ្រប់គ្រងអ្នកបង្កហិង្សា ជាមួយការពិចារណាត្រឹមត្រូវនៃបច្ចេកទេសទប់ស្កាត់ និងបន្ធូរបន្ថយស្ថានភាពគ្រោះថ្នាក់ ដូចជា ការចរចា និងការសម្របសម្រួល។

(ឃ)	ការសង្គ្រោះបឋម តម្រូវការចិត្តសាស្ត្ររបស់ជនជាប់ឃុំ និងកម្លាំងឆ្លើយតបនៅក្នុងបរិបទការងារពន្ធនាគារ ក៏ដូចជា ជំនួយ និងការថែទាសង្គម ដូចជា ការរកឃើញបញ្ហាសុខភាពផ្លូវចិត្តដំបូង។

២. មន្ត្រីពន្ធនាគារ ដែលទទួលបន្ទុកធ្វើការងារជាមួយប្រភេទជនជាប់ឃុំជាក់លាក់ ឬមន្ត្រីដែលបំពេញមុខងារជំនាញ ត្រូវទទួលការបណ្តុះបណ្តាលសមស្រប។

*វិធានទី៧៧*

មន្ត្រីពន្ធនាគារទាំងអស់គ្រប់ពេល ត្រូវប្រព្រឹត្ត និងអនុវត្តភារកិច្ចរបស់ ជាគំរូល្អដល់ជនជាប់ឃុំ និងដើម្បីទទួលបានការគោរពពីពួកគេ។

*វិធានទី៧៨*

១. រហូតមកដល់ពេលនេះ ប្រសិនអាចធ្វើបាន មន្ត្រីពន្ធនាគារ ត្រូវរួមបញ្ចូលចំនួនមន្ត្រីជំនាញគ្រប់គ្រាន់ ដូចជា អ្នកជំនាញវិកលវិទ្យា ចិត្តវិទ្យា និងសង្គមកិច្ច គ្រូ និងអ្នកបណ្តុះបណ្តាលវិជ្ជាជីវៈ។

២. សេវារបស់មន្ត្រីសង្គមកិច្ច គ្រូ និងអ្នកបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានធានាលើមូលដ្ឋានអចិន្ត្រៃយ៍មួយ ដោយមិនគិតថាជាការងារក្រៅម៉ោង ឬអ្នកស្ម័គ្រចិត្តឡើយ។

*វិធានទី៧៩*

១. ប្រធានពន្ធនាគារ ត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់សម្រាប់ភារកិច្ចរបស់ខ្លួន ដូចជា ចរិតលក្ខណៈសមត្ថភាពរដ្ឋបាល ការបណ្តុះបណ្តាលសមស្រប និងបទពិសោធ។

២. ប្រធានពន្ធនាគារត្រូវលះបង់ពេលវេលាទាំងអស់របស់ខ្លួនចំពោះការងារផ្លូវការ និងមិនត្រូវបានតែងតាំងធ្វើការក្រៅម៉ោងទេ។ គាត់ត្រូវស្នាក់នៅពន្ធនាគារ ឬបរិវេណជិតពន្ធនាគារ។

៣.	នៅពេលប្រធានពន្ធនាគារម្នាក់គ្រប់គ្រងពន្ធនាគារចាប់ពីពីរឡើងទៅ គាត់ត្រូវទៅពិនិត្យពន្ធនាគារនីមួយៗតាមចន្លោះពេលទៀងទាត់។ ត្រូវមានមន្ត្រីប្រចាំការម្នាក់សម្រាប់ពន្ធនាគារនីមួយៗក្នុងចំណោមពន្ធនាគារទាំងនេះ។

*វិធានទី៨០*

១. ប្រធានពន្ធនាគារ អនុប្រធានពន្ធនាគារ និងមន្ត្រីពន្ធនាគារភាគច្រើនផ្សេងទៀត ត្រូវចេះនិយាយ

ភាសាដែលជនជាប់ឃុំភាគច្រើននិយាយ ឬភាសាដែលជនជាប់ឃុំភាគច្រើនស្តាប់យល់។

២. នៅពេលណាដែលចាំបាច់ ត្រូវប្រើសេវារបស់អ្នកបកប្រែដែលមានសមត្ថភាពគ្រប់គ្រាន់ ។

*វិធានទី៨១*

១. ក្នុងពន្ធនាគារមួយសម្រាប់ជនជាប់ឃុំប្រុស និងស្រី ផ្នែកដែលឃុំស្ត្រី ត្រូវស្ថិតក្រោមការមើលខុសត្រូវរបស់មន្ត្រីជាស្ត្រី ដែលមានសោរពន្ធនាគារគ្រប់ផ្នែកទាំងនោះ។

២. ហាមមន្ត្រីបុរសចូលទៅកាន់ផ្នែកឃុំឃាំងជនជាប់ឃុំស្ត្រី លើកលែងមានការជូនដំណើរដោយមមន្ត្រីស្ត្រី។

៣. ជនជាប់ឃុំជាស្ត្រីត្រូវបានមើលថែទាំ និងគ្រប់គ្រងដោយមន្ត្រីស្ត្រីប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយនេះមិនមែនមានន័យថា លែងត្រូវការមន្ត្រីបុរស ជាពិសេស វេជ្ជបណ្ឌិត និងគ្រូ ក្នុងការអនុវត្តតួនាទីវិជ្ជជីវៈរបស់ពួកគេនៅក្នុងពន្ធនាគារ ឬផ្នែកនៃពន្ធនាគាសម្រាប់ស្ត្រីនោះទេ។

*វិធានទី៨២*

១. មន្ត្រីពន្ធនាគារ ក្នុងទំនាក់ទំនងរបស់ពួកគេជាមួយជនជាប់ឃុំ មិនត្រូវប្រើកម្លាំងទេ លើកលែងក្នុងករណីការពារខ្លួន ឬការព្យាយាមលួចរត់ ឬការប្រឆាំងជាក់ស្តែងដោយមាន ឬគ្មានសកម្មភាព នឹងបញ្ជាផ្អែកលើច្បាប់ ឬវិធាន។ មន្ត្រីពន្ធនាគារ មានសិទ្ធិប្រើកម្លាំង មិនត្រូវប្រើហួសតម្រូវការចាំបាច់ និងត្រូវរាយការណ៍ឧបទ្ទវហេតុនេះជូនប្រធានពន្ធនាគារភ្លាម។

២. មន្ត្រីពន្ធនាគារ ត្រូវទទួលការបណ្តុះបណ្តាលពិសេសជាក់ស្តែង ដើម្បីមានលទ្ធភាពតទល់នឹងជនជាប់ឃុំដែលមានចរិតឃ្លើន។

៣. លើកលែងស្ថានភាពពិសេស មន្ត្រីពន្ធនាគារដែលធ្វើកិច្ចការណា ដែលប៉ះពាល់ជនជាប់ឃុំដោយផ្ទាល់ មិនត្រូវមានអាវុធទេ។ ម្យ៉ាងទៀត ដោយមិនស្ថិតក្នុងស្ថានភាពណាមួយ មន្ត្រីពន្ធនាគារមិនត្រូវបានបំពាក់អាវុធឡើយ ប្រសិនមិនបានហ្វឹកហាត់ពីរបៀបប្រើអាវុធនោះ។

**អធិការកិច្ចផ្ទៃក្នុង និងអធិការកិច្ចពីស្ថាប័នខាងក្រៅ**

*វិធានទី៨៣*

១. គួរមានប្រព័ន្ធពីរសម្រាប់អធិការកិច្ចពន្ធនាគារទៀងទាត់ និងសេវាព្រហ្មទណ្ឌ៖

(ក) អធិការកិច្ចផ្ទៃក្នុង ឬអធិការកិច្ចរដ្ឋបាល ដែលអនុវត្តដោយរដ្ឋបាលពន្ធនាគារថ្នាក់កណ្តាល

(ខ) អធិការកិច្ចដោយស្ថាប័នខាងក្រៅ ដែលអនុវត្តស្ថាប័នផ្សេងពីរដ្ឋបាលពន្ធនាគារ ហើយដែលអាចរួមបញ្ចូលនូវស្ថាប័នមានសមត្ថកិច្ចថ្នាក់តំបន់ ឬអន្តរជាតិ។

២. ក្នុងករណីទាំងពីរ គោលបំណងនៃអធិការកិច្ច ត្រូវធានាថាការគ្រប់គ្រងពន្ធនាគារគឺស្របតាមច្បាប់ វិធាន គោលនយោបាយ និងនីតិវិធីដែលមានស្រាប់ ក្នុងគោលដៅដើម្បីសម្រេចគោលបំណងព្រហ្មទណ្ឌ និងការអប់រំកែប្រែ និងការការពារសិទ្ធិជនជាប់ឃុំ។

*វិធានទី៨៤*

១. អធិការមានសិទ្ធិអំណាចដូចខាងក្រោម៖

(ក) សិទ្ធិទទួលបានព័ត៌មានស្តីពីចំនួនជនជាប់ឃុំ និងទីកន្លែង និងទីតាំងឃុំឃាំង ក៏ដូចជាព័ត៌មានទាំងអស់ទាក់ទងនឹងការប្រព្រឹត្តរបស់ជនជាប់ឃុំ រួមនឹងរបាយការណ៍ និងលក្ខខណ្ឌនៃការឃុំឃាំង។

(ខ) មានសិទ្ធិជ្រើសរើសពន្ធនាគារសម្រាប់ធ្វើអធិការកិច្ច រួមទាំង ការមិនប្រកាសពីផែនការចុះពិនិត្យ និងពីជនជាប់ឃុំដែលត្រូវជួបសំភាសន៍។

(គ) ធ្វើការសំភាសន៍ជាឯកជន និងមានការសម្ងាត់ពេញលេញជាមួយជនជាប់ឃុំ និងមន្ត្រីពន្ធនាគារក្នុងពេលចុះត្រួតពិនិត្យរបស់ពួកគេ។

(ឃ) ផ្តល់អនុសាសន៍ជូនរដ្ឋបាលពន្ធនាគារ និងអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត។

២. ក្រុមអធិការរបស់ស្ថាប័នខាងក្រៅ ត្រូវរួមមានអធិការដែលមានសមត្ថភាព និងបទពិសោធន៍ ដែលតែងតាំងដោយអាជ្ញាធរមានសមត្ថកិច្ច និងត្រូវបញ្ចូលជំនាញការផ្នែកថែទាំសុខភាព ហើយក៏ត្រូវយកចិត្តទុកដាក់ដល់តុល្យភាពនៃចំនួនយេនឌ័រផងដែរ។

*វិធានទី៨៥*

១. អធិការកិច្ចនីមួយៗ ត្រូវធ្វើឡើងតាមរបាយការណ៍លាយលក្ខណ៍អក្សរ ដែលបានដាក់ជូនអាជ្ញាធរមានសមត្ថកិច្ច។ ការពិចារណាត្រឹមត្រូវបានផ្តល់ដើម្បីធ្វើឱ្យរបាយការណ៍អធិការកិច្ចពីខាងក្រៅផ្សព្វផ្សាយជាសាធារណៈ រួមទាំងទិន្នន័យផ្ទាល់ខ្លួនណាមួយស្តីពីជនជាប់ឃុំ លើកលែងតែពួកគេបានផ្តល់ការយល់ព្រមជាក់ច្បាស់។

២. រដ្ឋបាលពន្ធនាគារ ឬអាជ្ញាធរមានសមត្ថកិច្ច ត្រូវបង្ហាញប្រាប់នៅពេលសមស្របមួយ ថាតើពួកគេនឹងអនុវត្តអនុសាសន៍របស់អធិការកិច្ចខាងក្រៅនោះឬទេ។

II. វិធានជាក់លាក់ដែលអនុវត្តចំពោះប្រភេទជនជាប់ឃុំពិសេស

ក- ជនជាប់ឃុំកំពុងអនុវត្តទោសដែលបានចូលជាស្ថាពរ

គោលការណ៍ណែនាំ

*វិធានទី៨៦*

គោលការណ៍ណែនាំនានា ចាប់ពីពេលនេះតទៅ គឺមានបំណងបង្ហាញពីស្មារតីគ្រប់គ្រងពន្ធនាគារ និងគោលបំណងនានា ដែលមានបញ្ជាក់ក្នុងកថាដើមទី១ នៃវិធាននេះ។

*វិធានទី៨៧*

មុនបញ្ចប់ការអនុវត្តទោសតាមសាលក្រម/សាលដីកា ចាំបាច់ត្រូវចាត់វិធានការសំខាន់ៗដើម្បីធានាចំពោះជនជាប់ឃុំក្នុងវិលត្រឡប់ទៅក្នុងសង្គមបន្តិចម្តងៗ ។ វាអាស្រ័យលើករណី គោលបំណងនេះអាចសម្រេចបាន តាមរយៈរបបមុនដោះលែងដែលបានរៀបចំក្នុងពន្ធនាគារដដែល ឬក្នុងមន្ទីរឃុំឃាំសមស្រប ផ្សេងទៀត ឬតាមរយៈការដោះលែងសាកល្បងក្នុងដំណាក់កាលជំនុំជម្រះដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ដែលមិនត្រូវផ្ទុកផ្តាក់ឱ្យមន្ត្រីនគបាលទេ ប៉ុន្តែត្រូវរួមផ្សំនឹងជំនួយសង្គមកិច្ចប្រកបដោយប្រសិទ្ធភាព។

*វិធានទី៨៨*

១. ការប្រព្រឹត្តរបស់ជនជាប់ឃុំ ត្រូវបញ្ជាក់ច្បាស់ថា មិនមែនការជាបដិសេធរបស់ពួកគេចេញពីសហគមន៍ទេ ប៉ុន្តែពួកគេនៅតែជាផ្នែកមួយនៃសហគមន៍។ ដូច្នេះ ត្រូវស្វែងរកជំនួយពីភ្នាក់ងារសហគមន៍ក្នុងកិច្ចការស្តារនីតិសម្បទារបស់ជនជាប់ឃុំ។

២. ត្រូវមានទំនាក់ទំនងជាមួយភ្នាក់ងារសង្គមកិច្ចរបស់ពន្ធនាគារនីមួយៗ ដែលទទួលបន្ទុកកិច្ចការថែទាំ និការបង្កើនទំនាក់ទំនងជាមួយសាច់ញាតិរបស់ជនជាប់ឃុំ ជាមួយក្រុមគ្រួសារ និងជាមួយភ្នាក់ងារសង្គមសំខាន់ៗ។ ត្រូវមានវិធានការការពារ ជាអតិបរមា ស្របតាមច្បាប់ និងការជំនុំជម្រះក្តី សិទ្ធិទាក់ទងនឹងផលប្រយោជន៍រដ្ឋប្បវេណី សិទ្ធិសន្តិសុខសង្គម និងផលប្រយោជន៍ផ្សេងៗទៀតរបស់ជនជាប់ឃុំ។

*វិធាន ៨៩*

១. ដើម្បីឲ្យបានសម្រេចតាមគោលការណ៍ខាងលើនេះ ត្រូវអនុវត្តន៍តាមវិធីពិនិត្យព្យាបាលជនជាប់ឃុំម្នាក់ម្តងៗ ហើយដើម្បីឲ្យងាយក្នុងការអនុវត្តតាមវិធីនេះ ត្រូវចែកពួកជនជាប់ឃុំជាក្រុមៗ ទៅតាមប្រភេទ និងលក្ខណៈរបស់គេដើម្បីសម្រួលក្នុងកិច្ចការកែប្រែទៅតាមក្រុមនីមួយៗ។

២. ពន្ធនាគារទាំងនេះពុំចាំបាច់ផ្តល់សន្តិសុខក្នុងកម្រិតដូចៗគ្នានៅគ្រប់ក្រុមទាំងអស់ទេ។ ការផ្តល់សន្តិសុខ ក្នុងកម្រិតតិច ឬច្រើនត្រូវអាស្រ័យទៅលើសេចក្តីត្រូវការរបស់ក្រុមនីមួយៗ។ ពន្ធនាគារដែលមានលក្ខណៈចំហអាចមិនចាំបាច់រឹតបន្តឹងសន្តិសុខបង្ការការលួចរត់អាចបង្កើតឱ្យមានវិន័យស្វ័យគ្រប់គ្រងក្នុងក្រុម ដែលមានលក្ខណៈអំណោយផលដល់ការស្តារនីតិសម្បទាដល់ក្រុមជនជាប់ឃុំទាំងនោះ។

៣. នៅក្នុងពន្ធនាគារដែលមានលក្ខណៈបិទជិតខ្លាំងពុំគួរដាក់ជនជាប់ឃុំច្រើនហួសពេកដែលជាឧបសគ្គរាំងដល់ការអប់រំកែប្រែជាលក្ខណៈបុគ្គលឡើយ។ នៅប្រទេសខ្លះ គេហាមមិនឲ្យមានជនជាប់ឃុំច្រើនជាង ៥០០ នាក់ទេ នៅក្នុងពន្ធនាគារនីមួយៗ។ ចំពោះពន្ធនាគារដែលមានលក្ខណៈចំហ គួររក្សាចំនួនជនជាប់ឃុំឲ្យនៅតិចបំផុត។

៤. ម៉្យាងវិញទៀត មិនត្រូវទុកឱ្យមានពន្ធនាគារខ្នាតតូចពេកនោះទេព្រោះថាហេដ្ឋារចនាសម្ព័ន្ធផ្សេងៗអាចមិនត្រូវបានរៀបចំផ្គត់ផ្គង់បានត្រឹមត្រូវ។

*វិធាន ៩០*

កាតព្វកិច្ចរបស់សង្គម មិនមែនចប់នៅត្រឹមការដោះលែងជនជាប់ឃុំតែប៉ុណ្ណឹងទេ។ យ៉ាងណាមិញត្រូវតែមានទីភ្នាក់ងារឯកជន ឬទីភ្នាក់ងាររដ្ឋាភិបាល ដែលមានសមត្ថភាពអាចឧបត្ថម្ភដល់ពួក ដែលទើបនឹងរួចពីពន្ធនាគារនូវជំនួយដ៏ស័ក្តិសិទ្ធិគ្រប់ប្រការក្នុងទិសដៅបន្ថយការរើសអើងប្រឆាំងនឹងពួកគេ ហើយនិងក្នុងទិសដៅផ្តល់លទ្ធភាពសារជាថ្មីឡើងវិញ ក្នុងការរៀនរស់នៅក្នុងសង្គម។

## ការប្រព្រឹត្តទៅលើជនជាប់ឃុំ

*វិធាន ៩១*

ការប្រព្រឹត្តទៅលើជនជាប់ឃុំដែលត្រូវផ្តន្ទាទោសពន្ធនាគារ ឬទោសស្រដៀងគ្នាផ្សេងទៀត ត្រូវត្រូវធ្វើឡើងដោយមានគោលដៅច្បាស់លាស់។ ធម្មតារយៈពេលទទួលរងទោសអាចញ៉ាំងឱ្យជនជាប់ឃុំមានឆន្ទៈគោរពច្បាប់ និងចេះគិតគូរពីការប្រកបរបរចិញ្ចឹមជីវិតដោយខ្លួនឯង ក្រោយពេលដែលសាមីខ្លួនរួចពីពន្ធនាគារវិញ។ ក្នុងទិសដៅនេះ ត្រូវជំរុញជនជាប់ឃុំឲ្យចេះគោរពសេចក្តីថ្លៃថ្នូររបស់ខ្លួនគេ ព្រមទាំងឲ្យចេះស្គាល់ករណីយកិច្ច និងការទទួលខុសត្រូវផ្ទាល់ខ្លួន។

*វិធាន ៩២*

១. ដើម្បីសម្រេចតាមទិសដៅនេះ ត្រូវប្រើគ្រប់មធ្យោបាយណាដែលសមរម្យ ដោយមានជាអាទិ៍គឺការទ្រទ្រង់ សាសនា អាស្រ័យទៅលើលទ្ធភាពនៅក្នុងប្រទេសនិមួយៗ ការអប់រំ ការបណ្តុះបណ្តាលនិងការណែនាំខាងវិជ្ជាជីវៈ បញ្ហាការងារសង្គម កិច្ចការពន្យល់ណែនាំក្នុងរឿងរកការងារធ្វើ ការពង្រីកកាយវប្បកម្ម

និងពង្រឹងអត្តចរិតផ្នែកសីលធម៌ ឲ្យបានសមប្រទៅតាមសេចក្តីត្រូវការផ្ទាល់ខ្លួនរបស់ជនជាប់ឃុំម្នាក់ៗ ដោយពិនិត្យគិតគូរឲ្យបានដិតដល់ផងដែរទៅលើប្រវត្តិប្រព្រឹត្តបទល្មើស និងប្រវត្តិរូបផ្ទាល់ខ្លួន សមត្ថភាពខាងកម្លាំងកាយ និងកម្លាំងចិត្ត សម្បទា អារម្មណ៍ផ្ទាល់ខ្លួន រយៈពេលនៅក្នុងពន្ធនាគារ ហើយនឹងសេចក្តីប្រាថ្នារបស់គេក្រោយពេលដែលគេរួចពីពន្ធនាគារ។

២. សម្រាប់ជនជាប់ឃុំម្នាក់ ដែលត្រូវនៅជាប់ក្នុងពន្ធនាគារយ៉ាងយូរបង្គួរ ប្រធានពន្ធនាគារត្រូវតែបានទទួលសេចក្តីរាយការណ៍ឲ្យបានសព្វគ្រប់អំពីប្រការនានា ដែលនឹងរៀបរាប់នៅវគ្គខាងក្រោមនេះ។ សេចក្តីរាយការណ៍នេះ ត្រូវប្រគល់ឲ្យប្រធានពន្ធនាគារក្រោយពីពេលដែលគេបញ្ជូនជនជាប់ឃុំមកដល់ពន្ធនាគារភ្លាម។ នៅក្នុងសេចក្តីរាយការណ៍ ត្រូវរាប់បញ្ចូលកុំខាននូវរបាយការណ៍របស់គ្រូពេទ្យ ដែលមានគុណសម្បត្តិគ្រប់គ្រាន់ ជាពិសេសការពិនិត្យលក្ខណៈខាងផ្លូវកាយ និងផ្លូវចិត្តរបស់ជនជាប់ឃុំ។

៣. របាយការណ៍ និងឯកសារទាក់ទិនផ្សេងៗទៀត ត្រូវរក្សានៅក្នុងសំណុំឯកសារម្នាក់ៗ ដោយឡែកពីគ្នា ។ សំណុំឯកសារទាំងនេះ ត្រូវតែមានពត៌មានប្រចាំថ្ងៃស្តីអំពីហេតុការណ៍នានា ដែលទាក់ទងដល់ជនជាប់ឃុំម្នាក់ៗ ហើយរៀបតាមលំដាប់ត្រឹមត្រូវ ដើម្បីជាការងាយស្រួលដល់បុគ្គលិកធ្វើការ ជាពិសេសនៅពេលណាដែលគេត្រូវការពិនិត្យសំណុំរឿងរបស់ជនជាប់ឃុំ។

**ចំណាត់ថ្នាក់ជនជាប់ឃុំ និងការរៀបចំជនជាប់ឃុំតាមករណីបុគ្គលម្នាក់ៗ**

*វិធាន ៩៣*

១. គោលបំណងនៃការចែកប្រភេទជនជាប់ឃុំគឺ ៖

(ក) ដើម្បីឱ្យនៅដាច់ដោយឡែកអំពីពួកដែលអាចបង្កើតឱ្យមានឥទ្ធិពលអាក្រក់ទៅលើជនជាប់ឃុំឯទៀត ដោយ ផ្អែកទៅលើឯកសារឧក្រិដ្ឋ ឬចរិតឫកពារមិនល្អរបស់ពួកអស់ទាំងនោះ ។

(ខ) ចែកពួកជនជាប់ឃុំជាក្រុមៗ ដើម្បីឱ្យងាយស្រួលដល់ការគ្រប់គ្រង និងត្រួតពិនិត្យក្នុងការកសាងខ្លួនជនជាប់ឃុំ និងដើម្បីស្តារនីតិសម្បទាផ្នែកសង្គម។

២. តាមធម្មតា ការបែងចែកប្រភេទជនជាប់ឃុំឬការដាក់ជនជាប់ឃុំនៅតាមផ្នែកផ្សេងៗក្នុងពន្ធនាគារគឺធ្វើឡើងដើម្បីសម្រេចគោលដៅអប់រំកែប្រែជនជាប់ឃុំ។

*វិធាន ៩៤*

ក្រោយពេលដែលជនជាប់ឃុំចូលមកដល់ពន្ធនាគារភ្លាម ហើយក្រោយពីបានពិនិត្យសិក្សាឲ្យដឹងច្បាស់អំពីចរិយាសម្បត្តិរបស់ជនជាប់ឃុំណាដែលត្រូវជាប់ពន្ធនាគារយូរគួរសម ត្រូវរៀបចំឲ្យមានកម្មវិធី

សម្រាប់គ្រប់គ្រងអប់រំមួយឲ្យស្របទៅតាមលក្ខណៈនៃសេចក្តីត្រូវការផ្ទាល់ខ្លួន សមត្ថភាពខាងផ្លូវកាយ និងផ្លូវចិត្ត ហើយនឹងអារម្មណ៍របស់ជនជាប់ឃុំម្នាក់ៗ។

**បុព្វសិទ្ធិ**

*វិធាន ៩៥*

ការឲ្យមានបុព្វសិទ្ធិ ហើយនិងវិធីគ្រប់គ្រងខុសៗគ្នាទៅតាមលក្ខណៈ និងប្រភេទជនជាប់ឃុំ គួរតែបង្កើតឲ្យមាននៅគ្រប់ពន្ធនាគារ ដើម្បីអប់រំកសាងជនជាប់ឃុំឲ្យមានគំនិតមារយាទល្អ ឲ្យរីកចំរើននូវទឹកចិត្តចេះទទួលខុសត្រូវ ឲ្យចេះរក្សាការពារ ផលប្រយោជន៍ ហើយនឹងឲ្យមានសហប្រតិបត្តិការនៅក្នុងការគ្រប់គ្រងនេះ ។

**ការងារ**

*វិធានទី៩៦*

១. ជនជាប់ឃុំដែលបានប្រកាសទោស ត្រូវមានធ្វើការ និង/ឬចូលរួមយ៉ាងសកម្មក្នុងការស្តារនីតិសម្បទារបស់ពួកគេ ទៅតាមការសម្រេចរបស់គ្រូពេទ្យ ឬបុគ្គលិកវិជ្ជាជីវៈផ្នែកថែទាំសុខភាពដែលមានការទទួលស្គាល់ត្រឹមត្រូវ។

២. ផ្តល់ការងារចាំបាច់ធម្មតាគ្រប់គ្រាន់ ដើម្បីឱ្យជនជាប់ឃុំធ្វើយ៉ាងសកម្មសម្រាប់ថ្ងៃការងារធម្មតា។

*វិធានទី៩៧*

១. ពលកម្មរបស់ពន្ធនាគារ មិនមែនជាការងារធ្វើឱ្យមានការឈឺចាប់ទេ

២. ជនជាប់ឃុំមិនត្រូវចាត់ទុកជាទាសភាព ឬសេវភាពទេ

៣. មិនត្រូវប្រើជនជាប់ឃុំឱ្យធ្វើការសម្រាប់បុគ្គល ឬផលប្រយោជន៍ឯកជនរបស់មន្ត្រីពន្ធនាគារទេ។

*វិធាន ៩៨*

១. ត្រូវផ្តល់កិច្ចការប្រភេទណាដែលអាចជួយរក្សា ឬបង្កើនសមត្ថភាពពួកជនជាប់ឃុំ ឲ្យបានច្រើនបំផុត ក្នុងការប្រកបរបរចិញ្ចឹមជីវិតដោយសុចរិតក្រោយពេលចេញពីពន្ធនាគារទៅ។

២. ការហ្វឹកហ្វឺនវិជ្ជាជីវៈក្នុងផ្នែកពាណិជ្ជកម្ម ត្រូវតែឧបត្ថម្ភឲ្យបានច្រើន ដើម្បីឲ្យជនជាប់ឃុំចេះរកចំណេញ ក្នុងមុខរបរ ជាពិសេសសម្រាប់ពួកទោសក្មេងៗ។

៣. ត្រូវអនុញ្ញាតិឲ្យជនជាប់ឃុំជ្រើសរើសប្រភេទការងារដែលគេចង់ធ្វើ។ ប៉ុន្តែការជ្រើសរើសនេះត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌនៃរបបគ្រប់គ្រងនិងបទវិន័យពន្ធនាគារ។

*វិធាន ៩៩*

១. ការរៀបចំការងារ និងវិធីធ្វើការនៅក្នុងពន្ធនាគារ ត្រូវឲ្យមានលក្ខណៈស្រដៀងគ្នាទៅ នឹងប្រភេទនិងបែបបទ នៃការងារនៅក្រៅពន្ធនាគារ ដើម្បីជួយរៀបចំខ្លួនពួកជនជាប់ឃុំឲ្យបានជ្រួតជ្រាបយ៉ាងបំផុត ទៅក្នុងស្ថានភាពនៃរបរចិញ្ចឹមជីវិតធម្មតា ។

២. ក្នុងការការពារផលប្រយោជន៍ជនជាប់ឃុំ ហើយនឹងការហ្វឹកហ្វឺនរបរអាជីវកម្មត្រូវ ធ្វើយ៉ាងណាកុំបណ្ដាយឲ្យពួកជនជាប់ឃុំយល់ច្រឡំ ហើយមានចិត្តប៉ុនប៉ងចង់កេងចំណេញជាប្រាក់កាស អំពីកម្មវិធីអប់រំក្នុងពន្ធនាគារ។

*វិធាន ១០០*

១. ការហ្វឹកហ្វឺនក្នុងវិស័យឧស្សាហកម្មនិងកសិកម្ម គួរតែស្ថិតនៅក្រោមការត្រួតត្រា ដោយផ្ទាល់របស់រដ្ឋបាលពន្ធនាគារ ពុំគួរឲ្យនៅក្រោមការដឹកនាំនៃទីភ្នាក់ងារឯកជនជាប់កិច្ចសន្យាឡើយ។

២. ទីណាដែលជនជាប់ឃុំទៅធ្វើការ ទោះមិននៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលពន្ធនាគារក្ដី ក៏ត្រូវតែឲ្យមានមន្ត្រីពន្ធនាគារតាមមើលការខុសត្រូវជានិច្ចជាកាលដែរ។ លើកលែងតែការធ្វើការងារឱ្យស្ថាប័នផ្សេងទៀតរបស់រដ្ឋាភិបាល ប្រាក់ឈ្នួលពេញលេញស្របទៅតាមលទ្ធផលការងារដែលជនជាប់ឃុំធ្វើបានជាក់ស្ដែងត្រូវប្រគល់ទៅឱ្យរដ្ឋបាលពន្ធនាគារដោយបុគ្គលដែលទទួលប្រយោជន៍ពីលទ្ធផលនៃការងារទាំងនោះ។

*វិធាន ១០១*

១. ច្បាប់ដែលចែងឲ្យមានវិធីសម្រាប់ការពារដល់សន្តិសុខ និងសុខភាពរបស់អ្នកធ្វើការ ត្រូវយកទៅអនុវត្តន៍ឲ្យបានដូចគ្នានៅក្នុងពន្ធនាគារ។

២. ច្បាប់ត្រូវចែងឲ្យមានការសងជំងឺចិត្តដល់ពួកជនជាប់ឃុំ ក្នុងករណីដែលមានគ្រោះថ្នាក់ក្នុងការងារ ដោយរាប់បញ្ចូលទាំងជំងឺជំកាត់នានា ដែលបណ្ដាលមកពីលក្ខណៈនៃការងារផងដែរ ពោលគឺជនជាប់ឃុំត្រូវបានទទួលប្រាក់សងជំងឺចិត្ត ព្រមទាំងលក្ខខណ្ឌផ្សេងៗទៀតដូចគ្នានឹងប្រជាពលរដ្ឋឯទៀតៗដែរ។

*វិធាន ១០២*

១. ចំនួនពេលម៉ោងដែលច្រើនបំផុតប្រចាំថ្ងៃ ឬប្រចាំអាទិត្យសម្រាប់ឲ្យជនជាប់ឃុំធ្វើការត្រូវកំណត់តាមច្បាប់ ឬបទបញ្ជារដ្ឋបាល ដោយអនុលោមទៅតាមច្បាប់ប្រចាំតំបន់ ឬទំលាប់របស់អ្នកធ្វើការជាទូទៅ ។

២. ក្នុងការកម្រិតពេលម៉ោងសម្រាប់ធ្វើការ ត្រូវរក្សាទុកពេលសម្រាកយ៉ាងតិចណាស់មួយថ្ងៃក្នុងមួយអាទិត្យ។ លើសពីនេះទៅទៀត ត្រូវលៃពេលឲ្យបានគ្រប់គ្រាន់សម្រាប់ឲ្យពួកជនជាប់ឃុំបានសិក្សារៀនសូត្រ ហើយនឹងចូលរួមក្នុងសកម្មភាពឯទៀតៗដែលតម្រូវឲ្យដើម្បីឲ្យពួកគេអាចកសាងខ្លួនបាន។

*វិធាន ១០៣*

១. ត្រូវតែមានប្រព័ន្ធដើម្បីឲ្យប្រាក់ឈ្នួលស្មើគ្នាចំពោះការងាររបស់ពួកជនជាប់ឃុំ។

២. នៅក្នុងរបៀបចាត់ចែងប្រាក់ឈ្នួលនេះ ត្រូវអនុញ្ញាតឲ្យជនជាប់ឃុំមានសិទ្ធិចាយវាយ ភាគខ្លះនៃប្រាក់ដែលគេរកបាន ដើម្បីទិញរបស់របរខ្លះៗ ដែលអនុញ្ញាតិសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ឬផ្ញើជាប្រាក់ខ្លះទៅឲ្យបងប្អូនគ្រួសារគេ ។

៣. របៀបចាត់ចែងប្រាក់កាសរបស់ជនជាប់ឃុំ គឺត្រូវរៀបចំឲ្យមានការសន្សំលើផ្នែកណាមួយនៃចំណូល ដើម្បីទុកសម្រាប់ប្រគល់ឲ្យជនជាប់ឃុំនៅថ្ងៃចេញពីពន្ធនាគារ។

**ការអប់រំនិងការកំសាន្ត**

*វិធាន ១០៤*

១. ត្រូវចាត់ឲ្យមានការសិក្សាអប់រំនៅក្នុងពន្ធនាគារ ដើម្បីជាប្រយោជន៍ដល់ពួកជនជាប់ឃុំ ។ ការសិក្សាក្នុងវិស័យ សាសនា ក៏គួររៀបចំឲ្យមានដែរ ប្រសិនបើមានលទ្ធភាពអាចប្រព្រឹត្តទៅបាន។ កម្មវិធីអប់រំពួកជនជាប់ឃុំដែលមិនចេះអក្សរនិង ពួកជនជាប់ឃុំក្មេងៗត្រូវតែឲ្យមានដោយខានពុំបាន។ រដ្ឋបាលពន្ធនាគារត្រូវយកចិត្តទុកដាក់ឲ្យបានដិតដល់ចំពោះជនជាប់ឃុំក្រុមនេះ។

២. ប្រសិនបើអាចអនុវត្តទៅបាន គួរយកកម្មវិធីអប់រំដែលគេប្រើនៅសាលារៀនធម្មតា ទៅបញ្ចូលក្នុងកម្មវិធីអប់រំនៅសាលាក្នុងពន្ធនាគារ ដើម្បីជួយសំរួលឲ្យពួកជនជាប់ឃុំអស់ទាំងនេះ អាចបន្តការសិក្សាបានតទៅទៀតក្រោយពេលចេញពីពន្ធនាគារ។

*វិធាន ១០៥*

ដើម្បីថែរក្សាសុខភាពជនជាប់ឃុំទាំងខាងផ្លូវកាយ និងផ្លូវចិត្ត នៅក្នុងពន្ធនាគារត្រូវរៀបចំឲ្យមានកម្មវិធីផ្នែកវប្បធម៌ ហើយនិងពេលវេលាសម្រាប់សម្រាកកំសាន្ត។

**ការទាក់ទងក្នុងសង្គម និងការយកចិត្តទុកដាក់ក្រោយពីចេញពីពន្ធនាគារ**

*វិធាន ១០៦*

ត្រូវយកចិត្តទុកដាក់ជាពិសេសទៅលើការបង្កើនការទាក់ទង ឬការរក្សាការទាក់ទងរវាងជនជាប់ឃុំ និង ក្រុមគ្រួសាររបស់គេ ដើម្បីជាប្រយោជន៍ដល់ពួកគេទាំងសង្ខាង។

*វិធាន ១០៧*

ចាប់តាំងពីថ្ងៃដំបូងដែលជនជាប់ឃុំចូលមកដល់ពន្ធនាគារ ត្រូវយកចិត្តទុកដាក់គិតគូរអំពីអនាគតរបស់គេ ក្រោយពីពេលដែលគេបានចេញពីពន្ធនាគារទៅវិញ។ ត្រូវជួយណែនាំឲ្យជនជាប់ឃុំចេះរក្សាការទាក់ទងជាមួយអ្នកក្រៅ ឬចេះរក្សាទំនាក់ទំនង ជាមួយអ្នកក្រៅ ឬទីភ្នាក់ងារផ្សេងៗនៅក្រៅពន្ធនាគារ ដែលជាកត្តាអាចជួយឲ្យរីកចំរើនក្នុងការកសាងខ្លួនគេ និងជាការបង្កើនប្រយោជន៍ដល់បងប្អូនគ្រួសារគេផង។

*វិធាន ១០៨*

១. កិច្ចឧបត្ថម្ភ ឬទីភ្នាក់ងាររបស់រដ្ឋាភិបាលឬមិនមែនរដ្ឋាភិបាលទាំងឡាយណាដែលចាំជួយជនជាប់ឃុំដែលរួចពីពន្ធនាគារ ដើម្បីឲ្យរស់កើតនៅក្នុងសង្គមមនុស្ស ត្រូវគិតគូឲ្យដិតដល់ទៅលើសេចក្តីត្រូវការសំខាន់ៗរបស់ពួកគេដូចជា ៖ ឯកសារ ឬសំបុត្រស្នាមសំគាល់ខ្លួន ផ្ទះសម្បែងសម្រាប់រស់នៅ ការងារសម្រាប់ធ្វើដើម្បីបានកម្រៃចិញ្ចឹមជីវិត សម្លៀកបំពាក់គ្រប់គ្រាន់និងសមរម្យទៅតាមកាលៈទេសៈ និងធាតុអាកាស មធ្យោបាយគ្រប់គ្រាន់ដើម្បីធ្វើដំណើរទៅកាន់ទីដៅរបស់គេ និងថែរក្សាខ្លួនគេក្នុងរយៈពេលភ្លាមៗចាប់ពីថ្ងៃដែលគេចេញពីពន្ធនាគារ។

២. តំណាងទីភ្នាក់ងារនានាដែលត្រូវបានទទួលស្គាល់ ត្រូវមានលទ្ធភាពអាចចេញចូលពន្ធនាគារបាន ដើម្បីជួបប្រាស្រ័យជាមួយពួកជនជាប់ឃុំក្នុងការពិគ្រោះអំពីអនាគតរបស់ពួកគេ។

៣. ជាការកាន់តែប្រសើរ បើអាចធ្វើទៅបាន សកម្មភាពនានារបស់ទីភ្នាក់ងារផ្សេងៗគ្នាទាំងនេះ គួរធ្វើតាមរយៈការិយាល័យកណ្តាលមួយជាមួយគ្នាដើម្បីធានាឱ្យមានការប្រើប្រាស់កម្លាំងសរុបបានល្អប្រសើរ។

**ខ- ជនជាប់ឃុំមានពិការភាពផ្លូវចិត្ត និង/ឬបញ្ហាសុខភាព**

*វិធានទី១០៩*

១. មនុស្សដែលត្រូវបានរកឃើញថាគ្មានពាក់ព័ន្ធករណីព្រហ្មទណ្ឌ ឬមនុស្សដែលក្រោយមកបានធ្វើរោគវិនិច្ឆ័យរកឃើញថាមានជំងឺផ្លូវចិត្តធ្ងន់ធ្ងរ និង/ឬបញ្ហាសុខភាព ដែលកំពុងជាប់ពន្ធនាគារ ដែលធ្វើឱ្យលក្ខខណ្ឌជំងឺរបស់គេកាន់តែធ្ងន់ធ្ងរ មិនត្រូវបានឃុំឃាំងក្នុងពន្ធនាគារទេ និងត្រូវចាត់ចែងបញ្ជូនពួកគេទៅផ្នែកសេវាព្យាបាលផ្លូវចិត្តជាប្រញាប់។

២. ប្រសិនចាំបាច់ ជនជាប់ឃុំផ្សេងទៀត ដែលមានជំងឺផ្លូវចិត្ត និង/ឬបញ្ហាសុខភាព អាចត្រូវបានពិនិត្យ និងព្យាបាលនៅក្នុងបន្ទប់ឯកទេស ក្រោមការត្រួតពិនិត្យរបស់បុគ្គលិកថែទាំសុខភាពជំនាញ។

៣. សេវាថែទាំសុខភាព ត្រូវផ្តល់សេវាព្យាបាលវិលកចរិកដល់ជនជាប់ឃុំទាំងអស់ ដែលត្រូវការសេវានេះ។

*វិធាន ១១០*

ការដែលគួរឲ្យចង់បានគឺថា ប្រសិនបើឃើញថាមានការចាំបាច់គួរចាត់វិធានការ ដោយមានសម្រួលការជួយសម្រួលពីទីភ្នាក់ងារសមស្របឲ្យមានការតាមពិនិត្យព្យាបាលជាបន្តទៀតចំពោះការព្យាលបាលចិត្តវិកលប្រកបដោយនិរន្តរភាពក្រោយពេលចេញពីពន្ធនាគារ ហើយនិងការផ្តល់សេវាផ្លូវចិត្តសង្គមជាដើម។

**គ-ជនដែលត្រូវគេចាប់ខ្លួន ឬរង់ចាំសវនាការជំនុំជម្រះទោស**

*វិធាន ១១១*

១. ជនដែលត្រូវគេចាប់ខ្លួនឬជាប់ពន្ធនាគារដោយការចោទប្រកាន់ពីបទឧក្រិដ្ឋ ទោះនៅក្នុងកន្លែងឃុំឃាំងរបស់នគរបាល ឬនៅក្នុងពន្ធនាគារក្តី ដែលចៅក្រមមិនទាន់កាត់សេចក្តីផន្ទាទោសនៅឡើយនោះ ត្រូវចាត់ទុកថា " អ្នកជាប់ឃុំដែលមិនទាន់កាត់ទោស" ដូចដែលមានចែងនៅវិធានខាងក្រោមនេះ៖

២. ជនជាប់ឃុំទាំងឡាយដែលចៅក្រម ឬតុលាការពុំបានសម្រេចថាមានទោសនៅឡើយ ត្រូវចាត់ទុកជាមនុស្ស គ្មានកំហុស ហើយត្រូវបានទទួលការថែទាំដូចមនុស្សធម្មតា។

៣. ដោយពុំឲ្យមានទំនាស់ទៅនឹងវិធានស្របច្បាប់ដែលចែងអំពីកិច្ចការពារសេរីភាពរបស់មនុស្សម្នាក់ៗ ឬអំពីនីតិវិធីដែលត្រូវប្រតិបត្តិតាម ក្នុងករណីនៃពួកអ្នកជាប់ឃុំដែលមិនទាន់កាត់ទោស ពួកអ្នកជាប់

ឃុំឃាំងទាំងនេះ មានសិទ្ធិទទួលកិច្ចការពារតាមរបៀបពិសេសមួយ ដែលមានរៀបរាប់ក្នុងវិធានខាងក្រោមនេះ នៅក្នុងលក្ខខណ្ឌតម្រូវជាមូលដ្ឋានតែប៉ុណ្ណោះ។

*វិធាន ១១២*

១. អ្នកជាប់ឃុំឃាំងដែលគេមិនទាន់កាត់ទោស ត្រូវដាក់ឲ្យនៅដាច់ដោយឡែកអំពីជនជាប់ឃុំដែលបានទទួលការកាត់ទោស និងដាក់ទណ្ឌកម្មរួចហើយ។

២. ជនជាប់ឃុំក្មេងៗ ដែលពុំទាន់ទទួលការកាត់ទោស ត្រូវដាក់ឲ្យនៅដោយឡែកអំពីជនជាប់ឃុំពេញវ័យ ហើយបើតាមគោលការណ៍គួរដាក់ក្មេងៗទាំងនោះនៅក្នុងមន្ទីរដោយឡែក។

*វិធាន ១១៣*

ត្រូវឲ្យអ្នកជាប់ឃុំឃាំងដែលមិនទាន់បានកាត់ទោសត្រូវដេកតែម្នាក់ៗឯងនៅក្នុងបន្ទប់ដោយឡែកពីគ្នា ដោយត្រូវរៀបចំឲ្យមានធាតុអាកាសសមរម្យ ស្របទៅតាមទម្លាប់នៃតំបន់នីមួយៗរបស់ជនជាប់ឃុំម្នាក់ៗ។

*វិធាន ១១៤*

ចំពោះជនជាប់ឃុំប្រភេទនេះ ប្រសិនបើគេចង់ ត្រូវអនុញ្ញាតឲ្យគេទិញម្ហូបអាហារពីខាងក្រៅមកបរិភោគ ទោះតាមរយៈរដ្ឋបាលពន្ធនាគារ ឬតាមរយៈបងប្អូនគ្រួសារ ឬមិត្តភក្តិក្តី។ កាធ្វើបែបនេះ ត្រូវឲ្យស្របទៅតាមក្របខ័ណ្ឌនៃរបៀបរៀបរយរបស់ពន្ធនាគារ។ ផ្ទុយពីករណីនេះ រដ្ឋបាលពន្ធនាគារត្រូវទទួលបន្ទុកផ្តល់ម្ហូបអាហារដល់ពួកគេ។

*វិធាន ១១៥*

ត្រូវអនុញ្ញាតឲ្យពួកជនជាប់ឃុំប្រភេទនេះប្រើសម្លៀកបំពាក់របស់គេ ប្រសិនបើមានភាពស្អាតបាតត្រឹមត្រូវល្អ ។ ប្រសិនបើគេត្រូវប្រើសម្លៀកបំពាក់របស់ពន្ធនាគារ សម្លៀកបំពាក់ទាំងនេះមិនត្រូវឲ្យដូចគ្នាទៅនឹងខោអាវ របស់ពួកជនជាប់ឃុំដែលតុលាការបានកាត់ទោសស្ថាពររួចហើយនោះទេ។

*វិធាន ១១៦*

ជនជាប់ឃុំដែមិនទាន់ត្រូវបានកាត់ទោសត្រូវមានឱកាសធ្វើការងារ ប៉ុន្តែនេះមិនមែនជាកាតព្វកិច្ចដែលជនជាប់ឃុំប្រភេទនេះត្រូវតែធ្វើឡើយ។ ប្រសិនបើគេចង់ធ្វើការ គេត្រូវទទួលប្រាក់ឈ្នួលពីការងារនេះ។

*វិធាន ១១៧*

ជនជាប់ឃុំប្រភេទនេះ មានសិទ្ធិទិញ ឬអាចឲ្យបងប្អូនមិត្តភក្តិទិញឲ្យនូវឥវ៉ាន់ផ្សេងៗដូចជា សៀវភៅ កាសែត គ្រឿងប្រដាប់សរសេរ និងរបស់របរផ្សេងទៀត សម្រាប់ប្រើប្រាស់ឲ្យតែស្របទៅនឹងប្រយោជន៍នៃរដ្ឋបាលយុត្តិធម៌ និងសន្តិសុខ និងរបៀបរៀបរយល្អរបស់ពន្ធនាគារ។

*វិធាន ១១៨*

ប្រសិនបើពិតជាឈឺមែន ហើយបើគេមានប្រាក់គ្រប់គ្រាន់សម្រាប់បង់ថ្លៃព្យាបាលនិងស្របទៅតាមមូលហេតុជាក់ស្តែង ជនជាប់ឃុំប្រភេទនេះមានសិទ្ធិជួលគ្រូពេទ្យ ឬពេទ្យធ្មេញពីខាងក្រៅឲ្យមកព្យាបាលរោគគេនៅក្នុងពន្ធនាគារបាន។

*វិធានទី១១៩*

១. ជនជាប់ឃុំដែលមិនទាន់បានជំនុំជម្រះក្តី មានសិទ្ធិទទួលបានព័ត៌មានភ្លាមៗអំពីមូលហេតុនៃការឃុំខ្លួន និងអំពីការចោទប្រកាន់ពួកគេ។

២. ប្រសិនជនជាប់ឃុំដែលមិនទាន់បានជំនុំជម្រះក្តី មិនមានទីប្រឹក្សាច្បាប់តាមជម្រើសរបស់ខ្លួន ពួកគេមានសិទ្ធិទទួលបានទីប្រឹក្សាច្បាប់ដែលបានជ្រើសតាំងសម្រាប់ពួកគេដោយតុលាការ ឬអាជ្ញាធរផ្សេងទៀត ក្នុងគ្រប់ករណីដែលត្រូវការបំផុតដល់ផលប្រយោជន៍យុត្តិធម៌ និងដោយគ្មានការបង់ថ្លៃដោយជនជាប់ឃុំ ប្រសិនបើពួកគេមិនមានមធ្យោបាគ្រប់គ្រាន់ក្នុងការបង់ថ្លៃសេវា។ ការបដិសេធមិនឱ្យទទួលបានសេវាទីប្រឹក្សាច្បាប់ត្រូវមានការត្រួតពិនិត្យឡើងវិញដោយឯករាជ្យដោយគ្មានបង្អង់។

*វិធានទី១២០*

១. ការផ្តល់សិទ្ធិអំណាច និងបែបបទគ្រប់គ្រងសិទ្ធិទទួលបានទីប្រឹក្សាច្បាប់ ឬជំនួយផ្នែកច្បាប់សម្រាប់ការការពាររបស់ពួកគេគួរត្រូវបានគ្រប់គ្រងដោយគោលការណ៍ដូចគ្នា ដែលបានរៀបរាប់នៅក្នុងវិធានទី៦១។

២. តបតាមសំណើសុំ ជនជាប់ឃុំដែលមិនទាន់ជំនុំជម្រះក្តី ត្រូវទទួលបានឯកសារសំណេរសម្រាប់ការរៀបចំឯកសារការការពារក្តី រួមទាំងដំបូន្មានសម្ងាត់សម្រាប់ទីប្រឹក្សាច្បាប់ ឬអ្នកផ្តល់ជំនួយផ្នែកច្បាប់ពួកគេ។

## ឃ-ជនជាប់ឃុំក្នុងបទរដ្ឋប្បវេណី

*វិធាន ១២១*

នៅបណ្តាប្រទេសដែលច្បាប់អនុញ្ញាតឲ្យដាក់ពន្ធនាគារបង្ខំឲ្យសងបំណុល ឬតាមដីកាតុលាការ នៅក្នុងដំណើរការរឿងក្តីដែលមិនមែនជារឿងព្រហ្មទណ្ឌ ជនត្រូវគេដាក់ពន្ធនាគារ មិនត្រូវជាកម្មវត្ថុនៃការរិតត្បិតខ្លាំងក្លា ឬធ្ងន់ធ្ងរជាងការចាំបាច់សម្រាប់ការរក្សាសុវត្ថិភាពនិងសណ្តាប់ធ្នាប់ល្អឡើយ។ ការគ្រប់គ្រងថែរក្សាជនទាំងនោះ មិនត្រូវមានលក្ខខណ្ឌអនុគ្រោះតិចជាងអ្នកជាប់ឃុំរង់ចាំសវនាការឡើយ ប៉ុន្តែជននោះអាចនឹងតម្រូវឲ្យធ្វើការដែរ។

## ង-ជនដែលត្រូវបានចាប់ខ្លួន ឬឃុំខ្លួន ដោយគ្មានការចោទប្រកាន់ផ្លូវការ

*វិធាន ១២២*

ជនដែលត្រូវបានចាប់ខ្លួន ឬដាក់ពន្ធនាគារ ដោយគ្មានដីកាចោទប្រកាន់ មានសិទ្ធិទទួលបានការការពារដូចគ្នា ដូចដែលមានចែងក្នុងជំពូកទី I និងជំពូកទី II ផ្នែក គ នៃវិធាននេះ ដោយមិនទាន់គិតដល់បញ្ញត្តិទាំងឡាយដែលមានចែងក្នុងមាត្រា៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ បញ្ញត្តិពាក់ព័ន្ធនៃជំពូកទី II ផ្នែក ក នៃវិធាននេះក៏ត្រូវយកមកអនុវត្តផងដែរ ប្រសិនបើការអនុវត្តបញ្ញត្តិនោះ អាចជាផលប្រយោជន៍ដល់ក្រុមពិសេសនៃមនុស្សដែលស្ថិតក្នុងការឃុំឃាំង និងក្នុងករណីដែលគ្មានវិធានការអប់រំកែប្រែនិងស្តារសម្បទាណាអាចមានលក្ខណៈសមស្របសម្រាប់ជនដែលមិនទាន់ត្រូវបានផ្តន្ទាទោសស្តាពរពីបទល្មើសព្រហ្មទណ្ឌ។